# លក្ខណៈសំខាន់ៗនៃច្បាប់ប្រេងកាតទំនើប និងការ អនុវត្តន៍ប្រសើរជាអន្តរជាតិក្នុងឧស្សាហកម្មប្រេងកាតផ្នែក អាប់ស្ទ្រីម (UPSTREAM) សម្រាប់អ្នកពាក់ព័ន្ធស្វែងយល់



**សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន (CRRT)**

រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ខែតុលា ឆ្នាំ ២០១២

ឧបត្ថម្ភដោយ

# លក្ខណៈសំខាន់ៗនៃច្បាប់ប្រេងកាតធំនើប និងការអនុវត្តន៍ប្រសើរជាអន្តរជាតិ ក្នុងឧស្សាហកម្មប្រេងកាតផ្នែក អាប់ស្ទ្រីម(UPSTREAM) សម្រាប់អ្នកពាក់ព័ន្ធស្វែងយល់

អ្នកនិពន្ធ ៖ **បណ្ឌិត Makbul Rahim អ្នកប្រឹក្សាផ្នែកច្បាប់**

MMR Consultants

បោះពុម្ពផ្សាយដោយ ៖
សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន
រូបភាពគម្របខាងមុខ ៖ http://en.wikipedia.org

## ការបដិសេធទទួលខុសត្រូវ ៖

មតិយោបល់ទាំងឡាយដែលបានលើកឡើងនៅក្នុងឯកសារនេះ គឺជាមតិយោបល់របស់អ្នកនិពន្ធ ដោយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ម្ចាស់ជំនួយ និងអង្គការសម្ព័នភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធានឡើយ។ ទាំងអ្នកនិពន្ធ និងអ្នកបោះពុម្ពផ្សាយមិនបានផ្តល់ឯកសារនេះជាដំបូន្មានផ្នែកច្បាប់ ផ្នែកគណនេយ្យ ឬ សេវាវិជ្ជាជីវៈផ្សេងទៀតឡើយ។ យើងសូមលើកទឹកចិត្តឲ្យមានការផ្សព្វផ្សាយ និងបោះពុម្ព ផ្នែកណាមួយ ឬទាំងស្រុងនៃឯកសារនេះ ក្នុងទម្រង់មិនធ្វើពាណិជ្ជកម្ម ដោយគ្រាន់តែជូនដំណឹងមកកាន់អង្គការសម្ព័នភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន។

© សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន ឆ្នាំ ២០១២

# មាតិកា

សេចក្តីសង្ខេប ........................................................................... 6
សេចក្តីផ្តើម ................................................................................ 9
ក្របខណ្ឌច្បាប់............................................................................ 9
ការរៀបចំស្ថាប័ននិយ័តកម្ម .............................................................10
ការផ្សព្វផ្សាយគំរូកិច្ចព្រមព្រៀងប្រេងកាត និងល័ក្ខខណ្ឌនៃអាជ្ញាប័ណ្ណ..........11
ធនធានហិរញ្ញវត្ថុ ធនធានបច្ចេកទេស និងបទពិសោធន៍..........................11
នីតិវិធីដេញថ្លៃសម្រាប់ផ្តល់អាជ្ញាប័ណ្ណ និងកិច្ចព្រមព្រៀងប្រេងកាត .............11
ការចរចាជាមួយក្រុមហ៊ុន ...............................................................12
តំបន់ផ្តល់អាជ្ញាប័ណ្ណ.......................................................................12
ដំណាក់កាលរុករក ........................................................................13
កម្មវិធីការងាររុករក ......................................................................13
កាតព្វកិច្ចនៃការកាត់ប្រគល់ផ្ទៃដីទឹកមកវិញ/ ..........................................13
ការអនុម័តយល់ព្រមកម្មវិធី..............................................................14
ការរកឃើញប្រេងកាត.....................................................................14
រយៈពេលរក្សាទុក .........................................................................15
ផែនការអភិវឌ្ឍន៍...........................................................................15
ការរកឃើញឧស្ម័ន ........................................................................16
ការដុត ឬ ការបញ្ចេញឧស្ម័ន ............................................................16
បញ្ញត្តិប្រតិបត្តិការប្រេងកាត.............................................................16
ការពិនិត្យតាមដាន និងត្រួតពិនិត្យប្រតិបត្តិការប្រេងកាត ..........................17
សុខភាព និងសុវត្ថិភាព.....................................................................17
ការរាយការណ៍ដោយក្រុមហ៊ុនទទួលបានអាជ្ញាប័ណ្ណ ................................18

កម្មសិទ្ធិលើទិន្នន័យទាំងអស់ ........................................................ 18
ការរាយការណ៍ និងសវនកម្មលើចំណាយ និងចំណូលនៃប្រេងកាត............ 18
ការវាស់វែង និងអធិការកិច្ចប្រេងកាតនៅកន្លែងវាស់ ................................ 19
ការប្រគល់អាជ្ញាប័ណ្ណ ............................................................................ 19
ការបង្កើតអង្គភាពសម្រាប់គ្រប់គ្រងតំបន់ប្រេង និង ឧស្ម័នរួមគ្នាឆ្លងដែនអាជ្ញាប័ណ្ណ ឬ ព្រំដែនរបស់ប្រទេស.......................................................20
សិទ្ធិចេញចូលតំបន់ដែលបានផ្តល់អាជ្ញាប័ណ្ណ.......................................... 21
កិច្ចការពារ និងការបំពុលបរិស្ថាន.......................................................... 21
តួនាទីរបស់ភ្នាក់ងារនិយ័តករបរិស្ថាន ..................................................22
ផែនការ និងមូលនិធិសម្រាប់ការរុះរើចេញ ..............................................22
លិខិតុបករណ៍ស្តីពីលិខិតធានា និងប្រាក់ធានាការអនុវត្តការងារ ................23
លក្ខខណ្ឌសារពើពន្ធ.................................................................................23
ការប្រមូល និងគណនេយ្យសម្រាប់ការយកពន្ធ និងអាករសារពើពន្ធ............24
មូលនិធិគ្រប់គ្រងប្រាក់ចំណូលពីប្រេងកាត..............................................24
ផលប្រយោជន៍ក្នុងស្រុក ..........................................................................25
កម្មសិទ្ធិលើទ្រព្យសម្បត្តិ ........................................................................ 26
ការផ្គត់ផ្គង់ទីផ្សារក្នុងស្រុក........................................................................ 26
បញ្ញត្តិស្តីពីកិច្ចសន្យា និងច្បាប់ ............................................................ 26
បញ្ញត្តិរក្សាសិទ្ធិកែប្រែ (Grandfathering Provisions)..........................27
ការពិនិត្យមើលកិច្ចសន្យាឡើងវិញ...........................................................27
តម្លាភាពកិច្ចសន្យា និងភាពសម្ងាត់ .......................................................27
វិធានការតម្លាភាព.................................................................................... 28
ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ................................................29
ការអភិវឌ្ឍវិស័យប្រេងកាត...................................................................... 31

គោលនយោបាយប្រេងកាតជាតិ ........ 32
តួនាទីរបស់សង្គមស៊ីវិល ........ 33
កម្មសិទ្ធិ និងការគ្រប់គ្រងវិស័យប្រេងកាត ........ 34
ការរៀបចំស្ថាប័ន ........ 34
ក្តីបារម្ភរបស់ប្រទេសម្ចាស់ផ្ទះ ........ 35
ក្តីបារម្ភរបស់ក្រុមហ៊ុនវិនិយោគទុន ........ 36
បញ្ញត្តិប្រតិបត្តិការប្រេងកាត ........ 36
ការរៀបចំច្បាប់ប្រេងកាត ........ 36
លិខិតុបករណ៍ផ្តល់អាជ្ញាប័ណ្ណ ........ 38
ច្បាប់ពាក់ព័ន្ធក្នុងវិស័យប្រេងកាត និងតួនាទីផ្សេងៗគ្នារបស់ច្បាប់ទាំងនោះ .. 40
ការផ្តល់អាជ្ញាប័ណ្ណប្រេងកាត ........ 41
ប្រព័ន្ធកំណត់ព្រំដែនប្លុក ........ 43
រយៈពេលរុករក និងអភិវឌ្ឍន៍ ........ 43
បញ្ញត្តិស្តីពីការរកឃើញ ........ 44
បញ្ញត្តិស្តីពីហានិភ័យផ្តាច់មុខ ........ 44
របបសារពើពន្ធ ........ 44
ការប្រមូល ការផ្ទៀងផ្ទាត់ និងការប្រើប្រាស់ប្រាក់ចំណូលពីប្រេងកាត ........ 46
ការគ្រប់គ្រងប្រាក់ចំណូលពីប្រេងកាត ........ 47
បទដ្ឋានរាយការណ៍ និងគណនេយ្យអន្តរជាតិ ........ 48
ដំណើរការអនុវត្តការងារ ........ 49
របបនៃការរុះរើចេញ ........ 50
ផលប្រយោជន៍ក្នុងស្រុក និងការបណ្តុះបណ្តាល ........ 51
វិធានការអភិបាលកិច្ចល្អ ........ 53

គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI) ........................ 54
សុខភាព សុវត្ថិភាព និងបរិស្ថាន ........................................................ 56
ការហៀរប្រេង និងការបំពុលបរិស្ថាន.................................................... 57
តម្រូវសម្រាប់ទីផ្សារក្នុងស្រុក .............................................................. 58
បញ្ញត្តិរក្សាសិទ្ធិកែប្រែ (Grandfathering Provisions)............................ 58
ការគ្រប់គ្រងការរំពឹងទុករបស់សារធាណជន .......................................... 59

## សេចក្តីសង្ខេប

របាយការណ៍នេះ ពិនិត្យ ទៅលើបទបញ្ញត្តិប្រេងកាតដែលមានស្រាប់របស់ប្រទេសកម្ពុជា មានដូចជា បទបញ្ញត្តិប្រេងកាតឆ្នាំ ១៩៩១ គំរូកិច្ចសន្យាប្រេងកាតឆ្នាំ ២០០៤ និងច្បាប់បរិស្ថានឆ្នាំ ១៩៩៦ និងលើកឡើងពីរចនាសម្ព័ន្ធក្របខ័ណ្ឌច្បាប់ស្ថាប័នដែលមានជាធរមាន។

ជាក្របខ័ណ្ឌវិភាគមួយ សម្រាប់វាយតម្លៃលើច្បាប់ប្រេងកាតថ្មីដែលបានស្នើឡើង ដែលបច្ចុប្បន្ននេះកំពុងត្រូវបានរៀបចំឡើងដោយអាជ្ញាធរប្រេងកាតជាតិកម្ពុជា និងរដ្ឋាភិបាលកម្ពុជា ត្រូវបានផ្តល់ឲ្យក្នុងបរិបទនៃការអនុវត្តន៍ប្រសើរជាអន្តរជាតិ លើបទបញ្ញត្តិប្រេងកាត ពន្ធដារ និងកិច្ចព្រមព្រៀងប្រេងកាត។

មានការពិភាក្សាទៅលើការអនុវត្តន៍ប្រសើរជាអន្តរជាតិ ដែលគ្របដណ្តប់លើបទបញ្ញត្តិប្រេងកាត ផ្នែកអាប់ស្ទ្រីម (Upstream )និងពិនិត្យទៅលើជំពូកនានានៅក្នុងច្បាប់ប្រេងកាតថ្មីដែលបានស្នើឡើង និងស្នើឲ្យមានការកែប្រែទៅលើច្បាប់ពន្ធដែលទាក់ទងនឹងប្រតិបត្តិការប្រេងកាត និងការអភិវឌ្ឍទាំងឡាយនៅក្នុងច្បាប់ទាក់ទងផ្នែកអាប់ទ្រីម នៅក្នុងប្រទេសចំនួន៣ ដែលបាន ជ្រើសរើស មានប្រទេសទីម័រខាងកើត ឥណ្ឌូណេស៊ី និងប្រទេសហ្គាណា។ របាយការណ៍នេះលើកឡើងពីលទ្ធផល និងអនុសាសន៍នានារបស់ខ្លួន។

របាយការណ៍នេះ ពិនិត្យមើលទៅលើភាពចន្លោះប្រហោងនៃបទបញ្ញត្តិប្រេងកាតបច្ចុប្បន្ន និងគូសបញ្ជាក់ចំណុចដែលត្រូវកែលម្អ។ ជាសរុបលិខិតបទដ្ឋានច្បាប់ប្រេងកាតដែលមានស្រាប់ អាចធ្វើឲ្យកាន់តែប្រសើរទៅបានដោយការរួមបញ្ចូលគ្នាជាមួយនឹងការផ្តល់អាជ្ញាប័ណ្ណ តាមរយៈកិច្ច ព្រមព្រៀងប្រេងកាត ផ្តល់ឲ្យនូវការកែសម្រួល និងការកែលម្អឲ្យ

បានសមស្រប ត្រូវបានធ្វើឡើង នៅក្នុងលិខិតបទដ្ឋានច្បាប់ និងកិច្ចសន្យាដែលមានស្រាប់។

លក្ខណៈសំខាន់ៗនៃច្បាប់ប្រេងកាតទំនើបមួយ ត្រូវបានពិភាក្សាដើម្បីជួយដល់ការវាយតម្លៃទៅលើច្បាប់ប្រេងកាតថ្មី នៅពេលដែលច្បាប់នេះដាក់ឲ្យមានការពិនិត្យមើលជាសាធារណៈ។

# លក្ខណៈសំខាន់ៗនៃច្បាប់ ប្រេងកាតធំនើប

## សេចក្តីផ្តើម

វាគួរតែមានគោលនយោបាយស្តីពីប្រេងកាត ជាតិគ្រប់ជ្រុងជ្រោយមួយត្រូវបានបង្កើតឡើង ដោយមានការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធថ្នាក់ជាតិ ដើម្បីដឹកនាំ និងបង្កើតជាមូលដ្ឋានសម្រាប់ធ្វើការកាត់តែង និងបង្កើតច្បាប់ប្រេងកាតថ្មីៗ។

ឯកសារនេះ លើកឡើងពីទិដ្ឋភាពចំនួនពីរស្តីពីលក្ខណៈសំខាន់ៗនៃច្បាប់ប្រេងកាតថ្មី និងការអនុវត្តន៍ប្រសើរជាអន្តរជាតិនៅក្នុងឧស្សាហកម្មប្រេងកាតផ្នែកអាប់ទ្រីម សម្រាប់អ្នកពាក់ព័ន្ធស្វែងយល់។

## ក្របខណ្ឌច្បាប់

ក្របខ័ណ្ឌច្បាប់គួរ ៖ (១) ផ្តល់នូវភាពជាម្ចាស់ និងការគ្រប់គ្រងប្រេងកាតដែលមាន នៅក្នុងប្រទេសឲ្យស្ថិតនៅក្នុងការគ្រប់គ្រងរបស់រដ្ឋដែលតំណាងឲ្យពលរដ្ឋទាំងមូល (២) ផ្តល់នូវការគ្រប់គ្រង និងការត្រួតពិនិត្យ ប្រកបដោយប្រសិទ្ធភាពទៅលើប្រតិបត្តិការប្រេងកាតដោយរដ្ឋផ្ទាល់ ដើម្បីទទួលបានផលប្រយោជន៍ជាអតិបរមាដល់ពលរដ្ឋនៅក្នុងប្រទេស (៣) ចែងអំពីផែនការផ្តល់អាជ្ញាប័ណ្ណ និងកិច្ចព្រមព្រៀងប្រេងកាតឲ្យបានសមស្រេបដើម្បីកែសម្រួលប្រតិបត្តិការប្រេងកាត(៤) បង្កើតឲ្យមានបរិយាកាសអំណោយផលដើម្បីសម្រួលដល់ប្រតិបត្តិការ និងការវិនិយោគប្រកបដោយប្រសិទ្ធផលពីសំណាក់ឧស្សាហកម្មប្រេង (៥) ជានានូវការរុករកដោយហ្មត់ចត់ និងឆាប់រហ័ស និងធ្វើការអភិវឌ្ឍន៍ឲ្យទាន់ពេលវេលានៃការរកឃើញប្រេងកាតទាំងឡាយណា ព្រមទាំងការផលិតប្រកបដោយប្រសិទ្ធផល និងការអភិរក្សប្រេងកាត (៦) ផ្តល់នូវមូលដ្ឋានប្រតិបត្តិការស្តាពគ្នា និងការអនុវត្តដោយប្រសិទ្ធភាពនូវច្បាប់ប្រេងកាត និងការប្រព្រឹត្តដោយយុត្តិធម៌ចំពោះអ្នកចូលរួម និងអ្នក

ពាក់ព័ន្ធនៅក្នុងឧស្សាហកម្មនេះទាំងអស់ និង (៧) ឆ្លើយតបក្តីព្រួយបារម្ភស្របច្បាប់ជាមូលដ្ឋានរបស់វិនិយោគិន មានដូចជា សុវត្ថិភាពការងារ មានលទ្ធភាពស្តារការវិនិយោគមកវិញ និងការរៀបចំសេវាផ្តល់ហិរញ្ញប្បទាន ការបែងចែកផលចំណេញទៅឲ្យ ម្ចាស់ភាគហ៊ុនទាំងឡាយ ការរៀបចំប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព បរិយាកាសអំណោយផល ដល់ការធ្វើពាណិជ្ជកម្មប្រកបដោយប្រសិទ្ធផលដើម្បីរៀបចំប្រតិបត្តិការប្រេងកាត ដោយមិនមានការពន្យារពេលមិនសមហេតុផលក្នុងការធានានូវការព្រមព្រៀង និងការអនុញ្ញាតបន្ទាប់បន្សំដែលចាំបាច់នានា ស្ថេរភាពនៃល័ក្ខខ័ណ្ឌច្បាប់ និងកិច្ចសន្យា និងលក្ខខណ្ឌនៃការផ្តល់សិទ្ធិប្រើប្រាស់អាជ្ញាកណ្តាលអន្តរជាតិ និងសិទ្ធិជំរុញឲ្យអនុវត្តតាម។

## ការរៀបចំស្ថាប័ននិយ័តកម្ម

ស្ថាប័ននិយ័តកម្មគួរ ៖ (១) ចែងឲ្យមានអាជ្ញាធរនិយ័តករប្រេងកាតតែមួយគត់ ជាមួយប្រតិបត្តិការ ប្រកបដោយឯករាជ្យ និងអភិបាលកិច្ចសាជីវកម្មផ្ទៃក្នុងល្អ និងការធ្វើសេចក្តីសម្រេចប្រកបដោយតម្លាភាព ផ្អែកលើគោលបំណងល័ក្ខខ័ណ្ឌវិនិច្ឆ័យ (២) កាត់បន្ថយឆន្ទានុសិទ្ធិផ្នែករដ្ឋបាលក្នុងការធ្វើសេចក្តីសម្រេច និងចែងអំពីគណនេយ្យភាពចំពោះរដ្ឋសភា និងប្រទេសជាតិ (៣) ចែងអំពីនីតិវិធីពិនិត្យឡើងវិញ និងនីតិវិធីប្តឹងផ្តល់សម្រាប់សេចក្តីសម្រេចទាំងឡាយណាដែលមានការជំទាស់ពីភាគីដែលមិនសុខចិត្ត និង (៤) ចែងឲ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធិភាព រវាងនិយ័តករប្រេងកាត ក្រសួង និងស្ថាប័នផ្សេងៗទៀតដែលពាក់ព័ន្ធនៅក្នុងវិស័យប្រេងកាត ដូចជាស្ថាប័នបរិស្ថាន និងស្ថាប័នដទៃទៀតជាដើម។

## ការផ្សព្វផ្សាយគំរូកិច្ចព្រមព្រៀងប្រេងកាត និងល័ក្ខខណ្ឌនៃអាជ្ញាប័ណ្ណ

គួរមានការផ្សព្វផ្សាយជាសាធារណៈនូវគំរូកិច្ចព្រមព្រៀងប្រេងកាត និងល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណ ដែលបានធ្វើឡើងដោយរដ្ឋាភិបាល និងនីតិវិធីដេញថ្លៃដោយប្រកួតប្រជែងសម្រាប់ការដាក់ពាក្យដេញថ្លៃ និងលក្ខណៈវិនិច្ឆ័យលើគុណនិវឌ្ឍន៍សម្រាប់ធ្វើការវាយតម្លៃពាក្យដេញថ្លៃ និងសម្រាប់ការជ្រើសរើស។

## ធនធានហិរញ្ញវត្ថុ ធនធានបច្ចេកទេស និងបទពិសោធន៍

គួរមាននីតិវិធីផ្សេងៗដើម្បីធានាថា ក្រុមហ៊ុនទាំងឡាយដែលបានជ្រើសរើសសម្រាប់ការផ្តល់ អាជ្ញាប័ណ្ណនោះ មានធនធានហិរញ្ញវត្ថុ និងបច្ចេកទេស និងបទពិសោធន៍គ្រប់គ្រាន់ក្នុងប្រតិបត្តិការប្រេងកាត និងមានរបាយការណ៍តាមដានស្តីពីភាពជាប្រតិបត្តិករល្អក្នុងរកណីទាក់ទងនឹងប្រតិបត្តិករដែលបានស្នើសុំធ្វើប្រតិបត្តិការប្រេងកាត។

គួរមានដំណើរការពិនិត្យមើលទៅលើគុណវឌ្ឍន៍ជាមុន របស់ក្រុមហ៊ុនទាំងឡាយដើម្បីធានាថា សិទ្ធិនានាត្រូវបានផ្តល់ ឬ ចាត់ចែងទៅឲ្យតែក្រុមហ៊ុនប្រេងកាតទាំងឡាយណាដែលមាន ធនធាន បទពិសោធន៍ និងរបាយការណ៍តាមដានគ្រប់គ្រាន់ប៉ុណ្ណោះ។

## នីតិវិធីដេញថ្លៃសម្រាប់ផ្តល់អាជ្ញាប័ណ្ណ និងកិច្ចព្រមព្រៀងប្រេងកាត

គួរមានការប្រើប្រាស់វដ្តនៃការដេញថ្លៃដោយបើកចំហ និងនីតិវិធីដេញថ្លៃប្រកបដោយការប្រកួតប្រជែង សម្រាប់ការអញ្ជើញឲ្យចូលរួម និងការវាយតម្លៃទៅលើការដេញថ្លៃ ព្រមទាំងការជ្រើសរើសអ្នកឈ្នះ និងការ

ផ្តល់អាជ្ញាប័ណ្ណ។ គួរមានការបោះផ្សាយនូវនីតិវិធីដេញថ្លៃ សម្រាប់ផ្តល់អាជ្ញាប័ណ្ណ និងកិច្ចព្រមព្រៀងប្រេងកាត។ នីតិវិធីទាំងនេះគួរមានចែងពីនីតិវិធីដេញថ្លៃជាសាធារណៈ និងលក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃ ការដេញថ្លៃដោយសម្ព័ន្ធក្រុមហ៊ុន បូករួមទាំងភាគីប្រតិបត្តិករដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ប្រព័ន្ធវាយតម្លៃគុណវឌ្ឍន៍ជាមុនរបស់អ្នកដេញថ្លៃ និងការធានានូវគុណវឌ្ឍន៍ទាំងឡាយដែលតម្រូវឲ្យមានសម្រាប់អ្នកស្នើសុំ ឬ អ្នកដេញថ្លៃ ដូចជា ត្រូវមានធនធានបច្ចេកទេស និងហិរញ្ញវត្ថុ និងបទពិសោធន៍ភាពជាប្រតិបត្តិករ។

## ការចរចាជាមួយក្រុមហ៊ុន

គួរមាននីតិវិធីជាស្រេចសម្រាប់ការ ចរចាជាមួយក្រុមហ៊ុនទាំងឡាយដែលត្រូវបានជ្រើសរើស ដោយបរិយាយឲ្យបានលម្អិតអំពីស្ថាប័នដែលទទួលខុសត្រូវចំបងចំពោះការចរចា និងតួនាទីរបស់ក្រសួងនានា ឬ ក្រុមការងារចរចាអន្តរក្រសួង ការអនុម័តកិច្ចព្រមព្រៀងដែលបានចរចាដោយខុទ្ទកាល័យ ទីស្តីការគណៈរដ្ឋមន្ត្រី និងការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងដោយរដ្ឋសភា។

## តំបន់ផ្តល់អាជ្ញាប័ណ្ណ

គួរមានការកំណត់ព្រំដែន ឲ្យបានច្បាស់លាស់សម្រាប់តំបន់ក្នុងកិច្ចសន្យា ៥. តំបន់ផ្តល់អាជ្ញាប័ណ្ណ ដែលបង្កើតជាតំបន់រុករកដែលបានផ្តល់ឲ្យ។ ប្រព័ន្ធកំណត់ព្រំដែនតំបន់ទាំងឡាយ គួរត្រូវបានប្រើប្រាស់ជាឯកតាមូលដ្ឋានសម្រាប់តំបន់នោះដើម្បីធ្វើអត្តសញ្ញាណកម្ម កំណត់ព្រំដែន និងការប្រគល់ឲ្យវិញនូវតំបន់ដែលផ្តល់អាជ្ញាប័ណ្ណទៅតាមលំដាប់លំដោយត្រឹមត្រូវ។

## ដំណាក់កាលរុករក

គួរធ្វើការកំណត់ និងបែងចែកទៅជារយៈពេលចាប់ផ្តើមដំបូង និងរយៈពេលបន្ត។ ជាទូទៅ រយៈពេលរុករកមានគឺ ពី ៧ ទៅ ១០ឆ្នាំ ហើយរយៈពេលអភិវឌ្ឍន៍ និងផលិតកម្ម គឺពី ២៥ ទៅ ៣០ឆ្នាំទៅតាម អាយុកាលនៃប្លុកប្រេង។

## កម្មវិធីការងាររុករក

កម្មវិធីការងាររុករក និងការចំណាយអប្បបរមាដែលមានចែងនៅក្នុងអាជ្ញាប័ណ្ណ គួរមានលក្ខណៈជាកាតព្វកិច្ច និងត្រូវបានរៀបចំឡើងដើម្បីធានាឲ្យមានការរុករកដោយហ្មត់ចត់ និងដោយប្រសិទ្ធិភាព។ គួរធ្វើការកំណត់ពីកម្មវិធីការងាររុករក និងការចំណាយអប្បបរមាសម្រាប់អំឡុងពេលរុករកនីមួយៗ។ កម្មវិធីនេះរួមបញ្ចូលការសិក្សាស្ទង់រលកសំឡេងសាយស្មិច ការរៀបចំដំណើរការ ការបកស្រាយទិន្នន័យ និងការខួងអណ្តូងរុករក។ កម្មវិធីការវាយតម្លៃកម្មការងារ ការខួងដើម្បីវាយតម្លៃ និងការវាយតម្លៃទៅលើការរកឃើញ ត្រូវបានចែកដាច់ពីការខួងរុករកអប្បបរមា ហើយមិនមានការវាយតម្លៃទាំងស្រុង ទៅលើកម្មវិធីការងាររុករកអប្បបរមាឡើយ។ ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន គឺតម្រូវឲ្យធ្វើសម្រាប់ប្រតិបត្តិការរុករក រួមទាំងការសិក្សាស្ទង់រលកសំឡេងសាយស្មិច និងការខួងអណ្តូងផងដែរ។

## ភាតព្វកិច្ចនៃការកាត់ប្រគល់ផ្ទៃដី/ទឹកមកវិញ

គួរមានការប្រគល់ឲ្យវិញជាចាំបាច់នូវតំបន់ធ្វើការរុករក ទៅតាមភាគរយដែលបានបញ្ជាក់ នៅចុង ពេលនៃការរុករកនីមួយៗ។

## ការអនុម័តយល់ព្រមកម្មវិធី

គួរមានគម្រោងការមានប្រសិទ្ធភាព សម្រាប់អនុម័តយល់ព្រមរាល់ផែនការប្រតិបត្តិការប្រេងកាតសំខាន់ៗ ដូចជា ផែនការរុករក ផែនការពិនិត្យវាយតម្លៃ ផែនការអភិវឌ្ឍន៍ និងផលិតកម្មនៅគ្រប់ដំណាក់កាលទាំងអស់នៃប្រតិបត្តិការ។ គម្រោងការនេះរួមបញ្ចូលផងដែរនូវការអនុម័តកម្មវិធីការងាររុករក និងគម្រោងថវិកា ការអនុម័តផែនការពិនិត្យវាយតម្លៃ និងការនុម័តផែនការអភិវឌ្ឍន៍ធ្វើឡើងដោយនិយ័តករ។

## ការរកឃើញប្រេងកាត

គួរមានគម្រោងការប្រកបដោយប្រសិទ្ធភាព ស្តីពីការរកឃើញប្រេងកាតដែលមានចែងអំពីនីតិវិធីផ្សេងៗ ដែលត្រូវតាមដានដោយយោងទៅលើការរកឃើញ ដើម្បីធានាថា ការរកឃើញប្រេង និងឧស្ម័នទាំងឡាយត្រូវបានជូនដំណឹងភ្លាមៗ ពិនិត្យវាយតម្លៃ និងអភិវឌ្ឍយ៉ាងឆាប់រហ័ស ឬត្រូវបានប្រគល់ឲ្យវិញ។ ទាក់ទងនឹងការរកឃើញប្រេង និងឧស្ម័ន គួរមានល័ក្ខខ័ណ្ឌតម្រូវឲ្យរាយការណ៍ភ្លាមៗ និងកាតព្វកិច្ចដើម្បីអនុវត្តការសាកល្បងផលិតកម្ម និងការវាយតម្លៃពីលំហូរប្រេងកាតបន្ថែមទៀត។ វាអាចជាការសម្រេចរបស់ក្រុមហ៊ុន ថាតើការរកឃើញនោះមានសក្តានុពលពាណិជ្ជកម្ម ឬអត់ ក៏ប៉ុន្តែនីតិវិធីនេះត្រូវចែងពីផលវិបាកនៃការសម្រេចចិត្តនីមួយៗដែលធ្វើឡើងដោយក្រុមហ៊ុននោះ។ ប្រសិនបើការរកឃើញនោះមានសក្តានុពលពាណិជ្ជកម្ម នោះវាគឺជាភារកិច្ចរបស់ក្រុមហ៊ុនដែលត្រូវ ពិនិត្យវាយតម្លៃទៅលើការរកឃើញនោះ ហើយដាក់ជូននូវផែនការអភិវឌ្ឍន៍នៅក្នុងអំឡុងពេល កំណត់មួយ។ រយៈពេលពិនិត្យវាយតម្លៃ គឺពី២ ទៅ៤ឆ្នាំ សម្រាប់ការរកឃើញប្រេងឆៅ និងរហូតដល់ ៨ ឆ្នាំ សម្រាប់ការរកឃើញឧស្ម័នធម្មជាតិ។ ប្រសិនបើការរកឃើញនោះមិន

មានសក្តានុពលអាចធ្វើពាណិជ្ជកម្មបានទេនោះ វាជាជម្រើសរបស់រដ្ឋាភិបាលក្នុងការតម្រូវឲ្យក្រុមហ៊ុន ប្រគល់ឲ្យវិញនូវតំបន់ដែលរកឃើញនោះ។ ការពិនិត្យវាយតម្លៃលើការរកឃើញឧស្ម័ន ត្រូវរួមបញ្ចូលលទ្ធភាពទីផ្សារឧស្ម័នសម្រាប់ការរកឃើញឧស្ម័ន។

## រយៈពេលរក្សាទុក

មានលក្ខខណ្ឌចែងអំពីរយៈពេលរក្សាទុករហូតដល់ ៤ឆ្នាំ សម្រាប់ការរកឃើញបន្ទាប់បន្សំនូវប្រេងឆៅ ដែលមិនត្រូវបានចាត់ទុកថាមានសក្តានុពលពាណិជ្ជកម្ម ក៏ប៉ុន្តែតម្រូវឲ្យធ្វើការរុករកបន្តទៀតដើម្បី បង្កើតលទ្ធភាពធ្វើពាណិជ្ជកម្ម ប្រសិនបើក្រុមហ៊ុនមានឆន្ទៈអនុវត្តកម្មវិធី ការងារឲ្យបានពេញលេញ និងជាចាំបាច់នៅក្នុងអំឡុងពេលរក្សាទុកនេះ។

## ផែនការអភិវឌ្ឍន៍

គួរមានការដាក់ជូនទៅនិយ័តករនូវការវាយតម្លៃលម្អិត និងពាក្យស្នើសុំធ្វើការអភិវឌ្ឍការរកឃើញ ប្រេងកាត និងផែនការអភិវឌ្ឍន៍។ គួរមានបញ្ញត្តិចែងអំពីការកសាង និងការដាក់ជូននូវផែនការរុះ រើចេញ ដែលជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍សម្រាប់ប្រតិបត្តិការប្រេងកាត និងបង្កើតមូលនិធិ សម្រាប់ការរុះរើចេញ ដើម្បីផ្គត់ផ្គង់ដល់ការរុះរើចេញ និងដើម្បីធានានូវការអនុវត្តរបស់ខ្លួន។ ផែនការអភិវឌ្ឍន៍គួររួមបញ្ចូលសំណើសុំធ្វើការសាងសង់ ការដាក់ឲ្យផលិតកម្មដំណើរការ គ្រឿងបរិក្ខារដទៃទៀត ការអភិវឌ្ឍការដ្ឋាន ផែនការហិរញ្ញវត្ថុ ផែនការផលិតកម្ម និងប្រវត្តិផ្សេងៗ ផែនការរុះរើចេញ សំណើសុំមូលនិធិសម្រាប់ការុះរើចេញ និងក្នុងករណីទាក់ទងនឹងការអភិវឌ្ឍ ឧស្ម័ន ត្រូវដាក់ជូននូវសំណើកិច្ចព្រមព្រៀងលក់ឧស្ម័ន និងសំណើសុំធ្វើការបណ្តុះបណ្តាល និងជួលបុគ្គលិក

ក្នុងស្រុក សំណើសុំធ្វើលទ្ធកម្មទំនិញ និងសេវាកម្មក្នុងស្រុក ការសិក្សាពីហេតុ ប៉ះពាល់បរិស្ថាន និងសំណើបន្ធូរបន្ថយផលប៉ះពាល់។

## ការរកឃើញឧស្ម័ន

ក្នុងករណីរកឃើញឧស្ម័នលាយ (មិនសុទ្ធ) រដ្ឋាភិបាលគួរមានលទ្ធភាពយក និងប្រើប្រាស់ឧស្ម័ននោះសម្រាប់គម្រោងនានាក្នុងស្រុក ប្រសិនបើអ្នកម៉ៅការមិនអាច ឬ មិនប្រើប្រាស់ឧស្ម័ននោះទេ។ ក្នុងករណីរកឃើញឧស្ម័នសុទ្ធ នោះក្រុមហ៊ុនត្រូវពិនិត្យវាយតម្លៃ និងអភិវឌ្ឍការរកឃើញឧស្ម័ន នោះនៅក្នុងអំឡុងពេលកំណត់មួយដែលត្រូវបានអនុញ្ញាតឲ្យសម្រាប់ការងារនោះ ឬ ប្រគល់តំបន់ដែលរកឃើញឧស្ម័ននោះឲ្យមកវិញ។ វាគួរមានរយៈពេលរក្សាទុកសម្រាប់ការរកឃើញឧស្ម័ននានាដើម្បីបង្កើតទីផ្សារឧស្ម័ន និងលទ្ធភាពបង្កើតគម្រោងឧស្ម័ន។ បន្ទាប់ពីរយៈពេលរក្សាទុក កាតព្វកិច្ចគឺធ្វើការពិនិត្យវាយតម្លៃលើការរកឃើញឧស្ម័ន ឬ ធ្វើការប្រគល់តំបន់រកឃើញនោះឲ្យមក វិញ។

## ការដុត ឬ ការបញ្ចេញឧស្ម័ន

ការដុត ឬ ការបញ្ចេញឧស្ម័នចោលគួរត្រូវបានហាមឃាត់លើកលែងតែជួបគ្រោះអាសន្នផ្នែក ប្រតិបត្តិការប៉ុណ្ណោះ។

## បញ្ញត្តិប្រតិបត្តិការប្រេងកាត

ច្បាប់គួរតែមានផងដែរនូវល័ក្ខខ័ណ្ឌនានាទាក់ទងនឹង បញ្ញត្តិប្រតិបត្តិការប្រេងកាត ដែលបង្កើតឡើងដោយអាជ្ញាធរផ្តល់អាជ្ញាប័ណ្ណ ឬ និយ័តករ រួមទាំងល័ក្ខខ័ណ្ឌតម្រូវឲ្យរាយការណ៍ដំណើរការអនុម័ត ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ផែនការ និងមូលនិធិសម្រាប់ការរុះរើ សន្តិសុខសម្រាប់ការបំពេញការងារ និងការធានារ៉ាប់រងលើប្រតិបត្តិការ ការ

សម្របសម្រួលរវាងនិយ័តករ និងស្ថាប័នបរិស្ថានទាក់ទងនឹងតួនាទីរៀងៗខ្លួនរបស់ពួកគេ និងការគ្រប់គ្រងកិច្ចការដែលចែងក្នុងអាជ្ញាប័ណ្ណ និងការប្រើប្រាស់ប្រតិបត្តិការដើម្បីអភិវឌ្ឍតំបន់ប្រេង និងឧស្ម័ន។

## ការពិនិត្យតាមដាន និងត្រួតពិនិត្យប្រតិបត្តិការប្រេងកាត

គួរមានការពិនិត្យតាមដាន និងត្រួតពិនិត្យជាទៀងទាត់ទៅលើប្រតិបត្តិការប្រេងកាតដែលអនុវត្តដោយក្រុមហ៊ុនទទួលបានអាជ្ញាប័ណ្ណ ដូចជាការសិក្សារលកលំយោល (Seismic Shootings) ការខួង និងការដំឡើងសំណង់ និងឧបករណ៍នានា នីតិវិធីសម្រាប់គ្រោះថ្នាក់ សុខភាព និងសុវត្ថិភាពកន្លែងធ្វើការ ការឃ្លាំមើលវិធីសាស្ត្រអនុវត្តល្អនៅក្នុងការដ្ឋានប្រេង និងការគោរពតាមបទដ្ឋានឧស្សាហកម្មប្រេងកាតអន្តរជាតិ។

## សុខភាព និងសុវត្ថិភាព

គួរមានជំពូកសម្រាប់ធានាថា ប្រតិបត្តិការប្រេងកាតទាំងឡាយសុទ្ធតែអនុវត្តទៅតាមលក្ខខណ្ឌតម្រូវស្ដីពីសុខភាព សុវត្ថិភាព ឧស្សាហកម្មប្រេងកាតដែលប្រតិបត្តិការតាមបច្ចេកទេស បទដ្ឋានសិទ្ធិមនុស្ស និងបទដ្ឋានបរិស្ថាន ដែលមានចែងនៅក្នុងច្បាប់ដែលពាក់ព័ន្ធដែលអាចនឹងមានការកែប្រែ និងមានសុពលភាពពីពេលមួយទៅពេលមួយ ហើយជំពូកច្បាប់ដែលអសកម្ម ដែលរារាំងដល់ច្បាប់ និងបទដ្ឋាននានាដែលមានសុពលភាពនៅត្រឹមកាលបរិច្ឆេទចុះកិច្ចព្រមព្រៀងនោះ គួរត្រូវបានចាត់ទុកជាមោឃៈ។

## ការរាយការណ៍ដោយក្រុមហ៊ុនទទួលបានអាជ្ញាប័ណ្ណ

គួរមានគម្រោងការ គ្រប់ជ្រុងជ្រោយមួយស្តីពីការរាយការណ៍ដោយត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ធ្វើឡើងដោយក្រុមហ៊ុនទទួលបានអាជ្ញាប័ណ្ណ ដែលត្រូវរាយការណ៍ នៅក្នុងដំណាក់កាលនីមួយៗនៃប្រតិបត្តិការប្រេងកាតជូនទៅនិយ័តករប្រេងកាត។ ល័ក្ខខ័ណ្ឌតម្រូវឲ្យរាយការណ៍នេះរួមមានរបាយការណ៍ទៀងទាត់ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ស្តីពីប្រតិបត្តិការប្រេងកាត ការដាក់ជូនសំណាកគំរូសំខាន់ៗ និងបំណែកសមាសធាតុយកចេញពីក្នុងអណ្តូងដែលបានខួង ទិន្នន័យអណ្តូង និងការស្ទង់រលកសំឡេង ការបកស្រាយ និងការវាយតម្លៃដែលពាក់ព័ន្ធ។

## កម្មសិទ្ធិលើទិន្នន័យទាំងអស់

គ្រប់ទិន្នន័យទាំងអស់ត្រូវជាកម្មសិទ្ធិរបស់រដ្ឋ។

## ការរាយការណ៍ និងសវនកម្មលើចំណាយ និងចំណូលនៃប្រេងកាត

ការរាយការណ៍ពីថ្លៃចំណាយ និងប្រាក់ចំណូលពីប្រេងកាតជូនទៅនិយ័តករទៅតាមមូលដ្ឋានទៀងទាត់ ឧ. រៀងរាល់ខែ រៀងរាល់ត្រីមាសឆមាស និងរៀងរាល់ឆ្នាំ គឺមានសារសំខាន់ខ្លាំងណាស់។ នីតិវិធីគណនេយ្យដែលដាក់ភ្ជាប់ជាមួយនឹងកិច្ចព្រមព្រៀងប្រេងកាត នឹងផ្តល់ឲ្យនូវគោលការណ៍ណែនាំលម្អិតពាក់ព័ន្ធទៅនឹងថ្លៃចំណាយដែលទូទាត់យកវិញបាន ឬ មិនអាចទូទាត់យកវិញបាន។ ស្ថិតក្រោមការចំណាយរបស់ក្រុមហ៊ុន គួរមានការធ្វើសវនកម្មទៅលើគណនីទាំងឡាយ ថ្លៃចំណាយ និងប្រាក់ចំណូល និងការត្រួតពិនិត្យទៅលើប្រតិបត្តិការប្រេងកាតដែលធ្វើឡើងដោយ និយ័តករ។ ដើម្បីកាត់បន្ថយជាអប្បបរមានូវការ

រាយការណ៍ខុស និងការបំពានក្នុងការកំណត់ តម្លៃផ្ទេរ ត្រូវមានវិធាន និងនីតិវិធីផ្សេងៗជានាថា ក្រុមហ៊ុនទាំងឡាយមានបំណងលក់ទៅឲ្យ និងធ្វើដោះដូរជាមួយអ្នកទិញ ដែលជាសមាជិកតែក្នុងតម្លៃមួយដែល ផ្អែកទៅលើ ឬ ដែលសមមូលជាមួយនឹងការលក់ទៅឲ្យអ្នកទិញ ទាំងឡាយដែលមិនចូលជាសមាជិក និងអនុលោមទៅតាមលក្ខខ័ណ្ឌ ដែលអាចប្រៀបធៀបបាន រវាងភាគីអ្នកទិញទាំងឡាយដែលមិនមែន ជាសមាជិក។ នីតិវិធីនេះក៏ត្រូវយកទៅអនុវត្តផងដែរទៅលើការធ្វើលទ្ធ កម្មទំនិញ និងសេវាកម្មផ្សេងៗ។ គួរមានការ សម្របសម្រួល និងកិច្ច សហការគ្នារវាងស្ថាប័នជាតិ ដែលពាក់ព័ន្ធដើម្បីសម្រេចបានគោលដៅ និងគោលបំណងអភិវឌ្ឍ ការប្រមូលចំណូលឲ្យបានច្រើនបំផុត និងការ បន្ថែមតម្លៃក្នុងស្រុក កម្រិតខ្ពស់បំផុតដែលអាចធ្វើទៅបាន។

## ការវាស់វែង និងអធិការកិច្ចប្រេងកាតនៅកន្លែងវាស់

នីតិវិធីសម្រាប់ការវាស់វែងប្រេងកាតនៅកន្លែងវាស់ និងការត្រួតពិនិត្យជា ទៀងទាត់ទៅលើដំណើរការនេះ និងនីតិវិធីសម្រាប់ការកែសម្រួលប្រាក់ ចំណូល នៅក្នុងករណីមានការខូចខាតដែលបានរកឃើញកើតមាននៅ ក្នុងឧបករណ៍វាស់ គឺជាបញ្ញត្តិប្រតិបត្តិការយ៉ាងសំខាន់ និងអាចមានឥទ្ធិ ពលហិរញ្ញវត្ថុយ៉ាងច្រើនទៅលើភាគីទាំងឡាយ។

## ការប្រគល់អាជ្ញាប័ណ្ណ

ពាក់ព័ន្ធនឹងកិច្ចការនេះ គួរមានលក្ខខ័ណ្ឌតម្រូវនៃការយល់ព្រមទៅលើ ការប្រគល់ទៅឲ្យភាគីទីបី និងលក្ខខ័ណ្ឌតម្រូវដែលថាកាតព្វកិច្ចពីមុន នៅមានជាមួយនឹងអ្នកប្រគល់ដដែល ក្នុងករណី ដែលការប្រគល់ត្រូវ បានធ្វើឡើងក្នុងរង្វង់ក្រុមហ៊ុនដែលពាក់ព័ន្ធ ឬ នៅក្នុងក្រុមហ៊ុន សាជីវកម្ម តែមួយ។ អ្នកទទួល គួរជាក្រុមហ៊ុនដែលបានកំណត់គុណ

វឌ្ឍន៍ជាមុន។ គួរមានផងដែរ នូវល័ក្ខខ័ណ្ឌចែងពីការតម្រូវឲ្យបង់ពន្ធប្រាក់ចំណេញជាមូលធនសម្រាប់បុព្វលាភនៃការប្រគល់ ទាំងឡាយ ឬប្រាក់ចំណេញចែដន្យដែលទទួលបានដោយក្រុមហ៊ុនជាអ្នកប្រគល់។

## ការបង្កើតអង្គភាពសម្រាប់គ្រប់គ្រងតំបន់ប្រេង និង ឧស្ម័នរួមគ្នាឆ្លងដែនអាជ្ញាប័ណ្ណ ឬ ព្រំដែនរបស់ប្រទេស

គួរមានបញ្ញត្តិសម្រាប់ប្រើប្រាស់ និងការអភិវឌ្ឍរួមគ្នានៃតំបន់ប្រេងដែលត្រួតស៊ីគ្នាដែលឆ្លងដែនអាជ្ញាប័ណ្ណនៅក្នុងប្រទេស និងព្រំដែនឆ្លងប្រទេស។ ការអភិវឌ្ឍន៍រួមនៃតំបន់ប្រេងកាត ផ្តល់ឲ្យសម្រាប់តែទៅលើតំបន់ត្រួតស៊ីគ្នាទាំងនៅលើអាជ្ញាប័ណ្ណ ឬ ព្រំប្រទល់ដែលបានព្រមព្រៀងនៅក្នុងប្រទេស ឬតំបន់ត្រួតស៊ីគ្នារវាងព្រំដែនប្រទេស និងប្រទេស។ នៅពេលដែលករណីនេះកើតមាននៅក្នុងប្រទេសមួយ បញ្ញត្តិទូទៅ គឺថាអង្គភាពអភិវឌ្ឍរួមសម្រាប់តំបន់ត្រួតស៊ីគ្នា គឺជាកិច្ចការដំបូងបង្អស់ដែលត្រូវបង្កើត និងដោះស្រាយដោយយកចិត្តទុកដាក់រវាង់ក្រុមហ៊ុនទទួលបានអាជ្ញាប័ណ្ណទាំងឡាយ ដែលពាក់ព័ន្ធនៅក្នុងយុត្តាធិការដូចគ្នា តាមរយៈធ្វើការចរចាក្រោមការឯកភាពរបស់រដ្ឋទៅលើ កិច្ចព្រមព្រៀងបង្កើតអង្គភាពនោះ។ ក្នុងករណីមិនមានការព្រមព្រៀងគ្នារវាងក្រុមហ៊ុនទទួលបានអាជ្ញាប័ណ្ណ នោះរដ្ឋាភិបាលមានអំណាចធ្វើការកំណត់លើប្រការនិងល័ក្ខខ័ណ្ឌនានា ហើយដាក់ចេញនូវគម្រោងការអង្គភាពសមស្របមួយ ដោយអនុលោមទៅតាមការអនុវត្តន៍ប្រសើរជាលក្ខណៈអន្តរជាតិ។ ក្នុងករណី តំបន់ត្រួតស៊ីគ្នានេះឆ្លងព្រំដែនប្រទេស នោះចាំបាច់ត្រូវមានកិច្ចព្រមព្រៀងអភិវឌ្ឍរួមគ្នារវាងរដ្ឋ ជាប់គ្នាទាំងឡាយដែលពាក់ព័ន្ធ ហើយកិច្ចព្រមព្រៀងនេះ នឹងត្រូវអនុវត្តដោយរដ្ឋដែលពាក់ព័ន្ធ តាមរយៈការចង្អុលបង្ហាញរបស់ខ្លួន ទៅដល់ក្រុមហ៊ុនទទួលបានអាជ្ញាប័ណ្ណផ្សេងៗគ្នាដែលជាប់ពាក់ព័ន្ធនៅក្នុង យុត្តាធិការនីមួយៗ។

## សិទ្ធិចេញចូលតំបន់ដែលបានផ្ដល់អាជ្ញាប័ណ្ណ

គួរមាននីតិវិធីដែលមានភាពយុត្តិធម៌ និងមានតម្លាភាពដើម្បីធានាសិទ្ធិចេញចូលទៅកាន់តំបន់ ដែលបានផ្ដល់អាជ្ញាប័ណ្ណ ជាពិសេសតំបន់ប្រេងកាតនៅលើដី (Onshore) ទាក់ទងនឹងដីធ្លី ដោយក្នុងនីតិវិធីនោះ មានចែងអំពីការទទួលបានជាចាំបាច់នូវដីធ្លី និងប្រាក់សំណង និងការដោះស្រាយជម្លោះផ្សេងៗ ដែលកើតឡើងនៅទីនោះ។

## កិច្ចការពារ និងការបំពុលបរិស្ថាន

គួរមានបញ្ញត្តិគ្រប់គ្រាន់សម្រាប់ កាត់បន្ថយ និងគ្រប់គ្រងផលប៉ះពាល់អវិជ្ជមានជាអប្បរមានៃប្រតិបត្តិការប្រេងកាតទៅលើ បរិស្ថាន សង្គម និងសេដ្ឋកិច្ច របស់ប្រជាជនដែលរងផលប៉ះពាល់ តាមរយៈការផ្ដល់អាជ្ញាប័ណ្ណបរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រង។ កិច្ចការនេះរួមបញ្ចូលទាំងកិច្ចការពារបរិស្ថានប្រកបដោយប្រសិទ្ធភាពដើម្បីបង្ការ និងកាត់បន្ថយហានិភ័យនៃការបំពុលបរិស្ថាននៅលើដី និងនៅក្នុងសមុទ្រ ការអភិរក្សធនធានប្រេងកាត និងបរិស្ថាន វិធានការបង្ការសម្រាប់ទប់ស្កាត់ការធ្លាយប្រេង និងការដោះស្រាយឧប្បត្តិហេតុធ្លាយប្រេងនៅលើដី និងនៅក្នុងសមុទ្រ វិធានការរុះរើចេញឲ្យបានសមស្រប និងការស្ដារឡើងវិញនូវតំបន់ដែលរកឃើញនៅបន្ទាប់ពីចប់ប្រតិបត្តិការ បញ្ញត្តិនៃមូលនិធិសម្រាប់ការរុះរើ ចេញដើម្បីធានាដល់ដំណើរការអនុវត្តកាតព្វកិច្ចរុះរើចេញ ប្រព័ន្ធមានប្រសិទ្ធភាពសម្រាប់ការផ្ដល់អាជ្ញាប័ណ្ណបរិស្ថាន ការអនុវត្ត និងការយល់ព្រមទៅលើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ គោលការណ៍ស្ដីពីការទទួលខុសត្រូវចំពោះការបំពុលបណ្ដាលមកពីប្រតិបត្តិការប្រេងកាតគួរមាន ចែងនៅក្នុងច្បាប់ប្រេងកាត និងច្បាប់បរិស្ថានដែលពាក់ព័ន្ធ។

## តួនាទីរបស់ភ្នាក់ងារនិយ័តករបរិស្ថាន

តួនាទីរបស់ភ្នាក់ងារបរិស្ថានក្នុងការផ្តល់ឲ្យអាជ្ញាប័ណ្ណបរិស្ថាន និងក្នុងការពិនិត្យមើលទៅលើការ តាមដាន និងការត្រួតពិនិត្យបរិស្ថាន គឺមានសារៈសំខាន់។ ជំពូកទាំងនេះគួរកំណត់ពីតួនាទីផ្សេងៗគ្នារបស់និយ័តករប្រេងកាត និងនិយ័តករបរិស្ថានចំពោះកិច្ចការបរិស្ថាន និងការសម្របសម្រួលរវាងភ្នាក់ងារផ្សេងៗទៀតដែលពាក់ព័ន្ធ។ គួរមានបញ្ញត្តិស្តីពីរបេបច្បាប់បរិស្ថាននិងនីតិវិធី នីតិវិធីសម្រាប់ដោះស្រាយការធ្លាយប្រេងកក់ និងសារធាតុផ្សេងៗ និងការបំពុលនៅលើដី នៅក្នុងសមុទ្រ និងការបំពុលប្រភពទឹក។ គួរមានបញ្ញត្តិផែនការបំរុងឲ្យបានពេញលេញសម្រាប់ការធ្លាយប្រេង និងគ្រោះអាសន្នផ្សេងៗ និងការបង្កើតឲ្យមានមូលនិធិសម្រាប់ការធ្លាយប្រេងដែលផ្តល់ឲ្យដោយក្រុមហ៊ុនប្រេង ផ្សារភ្ជាប់ជាមួយផែនការធ្លាយប្រេងរបស់ជាតិ។

## ផែនការ និងមូលនិធិសម្រាប់ការរុះរើចេញ

ផែនការរុះរើចេញ ដែលឧបត្ថម្ភដោយមូលនិធិរុះរើសម្រាប់ការរុះរើចេញនូវរោងចក្រ និងប្រតិបត្តិការទាំងឡាយ ត្រូវតម្រូវឲ្យមាន ដែលជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍សម្រាប់អាជីវកម្ម។ មូលនិធិ សម្រាប់ការរុះរើចេញនេះ ត្រូវបានបង្កើតឡើងតាមរយៈប្រាក់វិភាគទានប្រចាំឆ្នាំដែលទទួលបានពីក្រុមហ៊ុនចុះកិច្ចសន្យា ស្របទៅតាមផែនការរុះរើដែលបានអនុម័ត។ ប្រាក់វិភាគទានប្រចាំឆ្នាំអាច កាត់រំលោះចេញសម្រាប់បង់ពន្ធលើប្រាក់ចំណូល។ ថវិកានេះត្រូវបានកាន់កាប់ដោយដាក់នៅក្នុងគណនីប្រាក់បម្រុងទុកនៅធនាគារ ក្រោមការគ្រប់គ្រងរួមគ្នារបស់រដ្ឋាភិបាល និងក្រុមហ៊ុនជាប់ កិច្ចសន្យា ហើយត្រូវបានប្រើប្រាស់សម្រាប់តែការរុះរើចេញប៉ុណ្ណោះ។ ចំនួនណាមួយដែលលើស នៅក្នុងមូលនិធិនេះ

នឹងត្រូវបានដកយកដោយក្រុមហ៊ុន ក៏ប៉ុន្តែនឹងត្រូវគ្រប់គ្រងជាប្រាក់ចំណូលសម្រាប់គោលបំណងពន្ធដារ ហើយចំនួនដែលខ្វះនៅក្នុងមូលនិធិនេះនឹងត្រូវដាក់បំពេញដោយក្រុមហ៊ុនជាប់កិច្ចសន្យា។

## លិខិតធានារ៉ាប់រងពីធនាគារ និងប្រាក់ធានាការអនុវត្តការងារ

ការអនុវត្តកាតព្វកិច្ចស្របច្បាប់នៅក្នុងកិច្ចសន្យា របស់ក្រុមហ៊ុនជាប់កិច្ចសន្យា នឹងត្រូវបានធានា តាមរយៈការធានារបស់ធនាគារ និងប័ណ្ណប្រាក់ ការធានារបស់ក្រុមហ៊ុនមេ ការធានារ៉ាប់រង ពេញលេញពីក្រុមហ៊ុនធានារ៉ាប់រងអន្តរជាតិ ដែលមានកេរ្តិ៍ឈ្មោះក្នុងការរ៉ាប់រងចំពោះបំណុល ប្រតិបត្តិការទាំងអស់របស់ប្រតិបត្តិករ និងសមាជិកសម្ព័ន្ធក្រុមហ៊ុន បូករួមទាំងការធានារ៉ាប់រង ចំពោះគ្រោះថ្នាក់ ការផ្ទុះ ការធ្លាយប្រេង។

## លក្ខខណ្ឌសារពើពន្ធ

លក្ខខណ្ឌសារពើពន្ធ ជាទូទៅ រួមបញ្ចូលទាំងប្រាក់រង្វាន់ចុះហត្ថលេខា និងប្រាក់រង្វាន់ផលិតកម្ម ថ្លៃឈ្នួលទីតាំង សួយសារអាករ ពន្ធលើប្រាក់ចំណូល ការចូលរួមរបស់រដ្ឋ និងល័ក្ខខ័ណ្ឌលើ ការប្រាក់ ថ្លៃដើម និងការបែងចែកប្រាក់ចំណេញ ស្ថិតក្រោមកិច្ចព្រមព្រៀងបែងចែកផលិតផល (PSA) តម្លៃប្រេងឆៅអន្តរជាតិ និងការកំណត់តម្លៃទីផ្សារសម្រាប់ឧស្ម័ន ការខាតបង់ដែលត្រូវទូទាត់ ក្នុងឆ្នាំខាងមុខ និងពន្លឿនការកាត់រំលោះពន្ធលើប្រាក់ចំណូល។ គួរមានបញ្ញត្តិចែងពីសមាសភាគពន្ធ លើកំណើនធនធាននៅក្នុងការយកពន្ធ ដូចជា ពន្ធលើប្រាក់ចំណេញ ដើម្បីផ្តល់ឲ្យរដ្ឋាភិបាលនូវ ចំណែកឲ្យបានច្រើនក្នុងករណីដែលទទួលបានផលចំណេញ និងប្រាក់ចំណេញចៃដន្យខ្ពស់។ គួរមានភាពច្បាស់លាស់ និង

ប្រាកដប្រជាចំពោះប្រការ និងល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណ ដើម្បីសម្រួល ឲ្យមានប្រាក់ចំណេញសមស្របដល់វិនិយោគិន និងការបែងចែកនូវប្រាក់ចំណេញឲ្យបានយុត្តិធម៌ ទៅដល់រដ្ឋ តាមរយៈកំណើនរបបសារពើពន្ធដែលផ្តល់នូវចំណែកកាន់តែច្រើនទៅឲ្យរដ្ឋ ជាមួយនឹងទទួលបានប្រាក់ចំណេញកាន់តែខ្ពស់ ក៏ប៉ុន្តែវាមិនប៉ះពាល់ដល់ការអភិវឌ្ឍវិស័យតូចៗឡើយ។ គួរមានបញ្ញត្តិចែងអំពីល័ក្ខខ័ណ្ឌផលប្រយោជន៍ដែលបានអនុវត្តសម្រាប់អ្នកចូលរួម ឬ ល័ក្ខខ័ណ្ឌសមស្របដទៃទៀតសម្រាប់ការចូលរួមរបស់រដ្ឋ ដើម្បីធានាថា ហានិភ័យនៃការរុករក និងការពិនិត្យវាយតម្លៃ គឺជាបន្ទុករបស់ក្រុមហ៊ុនប្រេងទាំងឡាយ។

## ការប្រមូល និងគណនេយ្យសម្រាប់ការយកពន្ធ និងអាករសារពើពន្ធ

គួរមានជាស្រេចនូវនីតិវិធីសមស្រប និងមានប្រសិទ្ធភាពដើម្បីធានាដល់ការប្រមូល និងគណនេយ្យឲ្យបានត្រឹមត្រូវសម្រាប់ការយកពន្ធ និងអាករសារពើពន្ធ ដូចជា ប្រាក់រង្វាន់ ថ្លៃឈ្នួលទីតាំង សួយសារអាករ ពន្ធលើប្រាក់ចំណូល និងពន្ធលើចំណូលចៃដន្យដែលមានកំណើនខ្ពស់ខ្លាំង និងការបែងចែកនូវប្រាក់ចំណេញពីប្រេង ពន្ធគយ និងពន្ធបន្ទាប់បន្សំ ការធានាការកត់ត្រា និងការរាយការណ៍ប្រកបដោយតម្លាភាពលើថ្លៃចំណាយ និងថ្លៃប្រតិបត្តិការពីសំណាក់ក្រុមហ៊ុននានា រួមទាំងប្រាក់ចំណូល និងវិធានការទល់ទៅនឹងការរំលោភបំពានក្នុងការកំណត់តម្លៃផ្ទេរ។

## មូលនិធិគ្រប់គ្រងប្រាក់ចំណូលពីប្រេងកាត

គួរមានបញ្ញត្តិស្តីអំពីមូលនិធិគ្រប់គ្រងប្រាក់ចំណូលពីប្រេងកាត ដើម្បីចែងពីការប្រើប្រាស់ ការគ្រប់គ្រង និងការបែងចែកនូវប្រាក់ចំណូលពី

ប្រេងកាតសម្រាប់ឆ្លើយតបទៅនឹងគម្រោងថវិកាទៅលើ វិស័យអាទិភាព សំខាន់ៗ ការរក្សាស្ថេរភាពនៃដំណើរការរង្គោះរង្គើរផ្នែកសេដ្ឋកិច្ច ភាពប្រែប្រួលនៃតម្លៃប្រេង និងមូលនិធិអន្តរជំនាន់សម្រាប់មនុស្សជំនាន់ក្រោយៗ។ គោលដៅនៃមូលនិធិនេះ គឺដើម្បី បង្កើតជាគម្រោងចំណាយការរក្សាស្ថេរភាពនៃលំហូរប្រាក់ចំណូល និងការសន្សំប្រាក់សម្រាប់មនុស្សជំនាន់ក្រោយ និងដើម្បីផ្តល់ឲ្យនូវក្រោយយុគសម័យប្រេងកាតនូវ វិបត្តិសេដ្ឋកិច្ច កំរិតអប្បរមា។ គួរមាននីតិវិធីសម្រាប់ការគ្រប់គ្រង និងការវិនិយោគថវិការបស់មូលនិធិ ដាក់ បញ្ចូលមូលនិធិនេះទៅក្នុងការគ្រប់គ្រង គម្រោងថវិកា និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ រដ្ឋាភិបាល បញ្ចៀសនូវជំងឺហូឡង់ (Dutch disease) និងបណ្តាសាធនធាន និងនីតិវិធីដើម្បីធានាថា ថវិកាទាំងនេះប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ហើយ មូលនិធិទាំងនេះត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការថវិការួមថ្នាក់ជាតិ ធានាឲ្យមាននូវពរជ័យពីធនធាន និងការធានាឲ្យមានការគ្រប់គ្រងឲ្យបានត្រឹមត្រូវ និងបញ្ចៀសនូវផលប៉ះពាល់អវិជ្ជមាននៃប្រាក់ចំណូលពីប្រេងកាត។

## ផលប្រយោជន៍ក្នុងស្រុក

បញ្ញត្តិស្តីពីផលប្រយោជន៍ក្នុងស្រុក ត្រូវដាក់បញ្ចូលនូវការប្រើប្រាស់ទំនិញ និងសេវាកម្មក្នុង ស្រុក ការជួលពលរដ្ឋក្នុងស្រុក ការបណ្តុះបណ្តាលពលរដ្ឋក្នុងស្រុក ការផ្តល់ថវិកាសម្រាប់ការ បណ្តុះបណ្តាលដល់និយោជិត និងការចូលវិភាគទានក្នុងមូលនិធិសម្រាប់ការបណ្តុះបណ្តាលរបស់ជាតិដើម្បីបង្កើនសមត្ថភាពក្នុងវិស័យប្រេងកាត។

## កម្មសិទ្ធិលើទ្រព្យសម្បត្តិ

ទ្រព្យសម្បត្តិ និងសម្ភារៈបរិក្ខារ ដែលនាំចូលមកក្នុងប្រទេស ឬក៏សម្ភារ ដែលទូទាត់ថ្លៃចំណាយ រួចហើយ គឺជាកម្មសិទ្ធិរបស់រដ្ឋ។។ គួរមាន មាត្រាដែលផ្តល់ឲ្យរដ្ឋាភិបាលនូវអំណាចដើម្បីតម្រូវ ឲ្យក្រុមហ៊ុនត្រូវរុះរើ ចេញនូវទ្រព្យសម្បត្តិនានា ដែលលែងមានប្រយោជន៍ប្រើប្រាស់បើទោះ បីជាបានផ្ទេរជាកម្មសិទ្ធិទៅឲ្យរដ្ឋហើយក៏ដោយ។

## ការផ្គត់ផ្គង់ទីផ្សារក្នុងស្រុក

គួរមានមាត្រា ដែលតម្រូវឲ្យក្រុមហ៊ុនជាប់កិច្ចសន្យាចែកភាគហ៊ុនដោយ ផ្អែកលើសមាមាត្រនៃប្រេងឆៅ និងឧស្ម័ន ស្ថិតក្រោមអាជ្ញាប័ណ្ណ ឬ កិច្ចព្រមព្រៀងបែងចែកផលិតផល PSA សម្រាប់បំពេញតម្រូវការទីផ្សារ ក្នុងស្រុក។

## បញ្ញត្តិស្តីពីកិច្ចសន្យា និងច្បាប់

បញ្ញត្តិស្តីពីកិច្ចសន្យា និងច្បាប់ ដែលគួរមានចែងនៅក្នុងក្របខ័ណ្ឌច្បាប់ ដែលរួមមានការដោះស្រាយជម្លោះ មាត្រាសើរើកិច្ចសន្យាឡើងវិញ មាត្រាស្តីពីស្ថេរភាពកិច្ចសន្យា តម្លាភាពកិច្ចសន្យា និងល័ក្ខខ័ណ្ឌផ្លូវច្បាប់ ដទៃទៀតដូចជា ការមិនទទួលខុសត្រូវទៅលើហេតុការណ៍ប្រធានស័ក្តិ និងច្បាប់យកមកអភិបាល ។ ជំពូកនេះគួរបញ្ចូលនូវមាត្រា ដែលចែង អំពីអ្នកជំនាញ ការអន្តរជាតិសម្រាប់បញ្ហាបច្ចេកទេស និងអាជ្ញា កណ្តាលអន្តរជាតិសម្រាប់ដោះស្រាយជម្លោះផ្សេងៗ។ ក្រុមហ៊ុនប្រេង ទាំងឡាយចង់ឃើញពីមាត្រាស្តីពីស្ថេរភាពសារពើពន្ធ និងមាត្រាស្តីពី ស្ថេរភាពកិច្ចសន្យា។

## បញ្ញត្តិរក្សាសិទ្ធិកែប្រែ ( Grandfathering Provisions )

វាជាការអនុវត្តទូទៅមួយ ដែលត្រូវមានបញ្ញត្តិស្តីពីការរក្សាសិទ្ធិកែប្រែ សម្រាប់អាជ្ញាប័ណ្ណ និងកិច្ចព្រមព្រៀងប្រេងកាតចាស់ដែលនៅមានសុពលភាព នៅពេលដែលច្បាប់ប្រេងកាតថ្មីមួយត្រូវបានអនុម័ត។ បញ្ញត្តិនេះ ទាក់ទងនឹងភាពសមស្របនៃការរៀបចំជាអន្តរកាល សម្រាប់ជួយសង្គ្រោះដល់សិទ្ធិប្រេងកាតដែលមានជាធរមាន និងផ្តល់នូវយន្តការសមស្របនានា សម្រាប់ធ្វើការកែប្រែនូវកិច្ចព្រមព្រៀងប្រេងកាតដែលមានជាធរមាន ចូលទៅក្នុងគម្រោងការនៃច្បាប់ថ្មីដោយផ្អែកលើមូលដ្ឋានឯកភាពរួមមួយដែលគូភាគីព្រមទទួលយក។ មាត្រារក្សាសិទ្ធិកែប្រែអន្តរកាលបែបនេះ គួរតែមានចែងនៅក្នុងច្បាប់ថ្មី។

## ការពិនិត្យមើលកិច្ចសន្យាឡើងវិញ

គួរមានមាត្រា ចែងអំពីការពិនិត្យមើលឡើងវិញតាមពេលកំណត់ទៅលើដំណើរការអនុវត្តកិច្ចសន្យាជារួម ព្រមទាំងប្រការ និងល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងទាំងឡាយ ក៏ដូចជានីតិវិធី និងបែបបទសម្រាប់ការកែប្រែដែលមានការព្រមព្រៀងគ្នាទៅតាមកាលៈទេសៈប្រែប្រួល។

## តម្លាភាពកិច្ចសន្យា និងភាពសម្ងាត់

ពាក់ព័ន្ធនឹងបញ្ញត្តិស្តីពីភាពសម្ងាត់ បញ្ញត្តិទាំងនេះជាទូទៅចែងអំពីភាពសម្ងាត់នៃកិច្ចព្រមព្រៀង ភាពសម្ងាត់នៃទិន្នន័យបច្ចេកទេស និងព័ត៌មានដែលផ្តល់ឲ្យក្រោមកិច្ចព្រមព្រៀង និងភាពសម្ងាត់នៃព័ត៌មានសំខាន់ៗផ្នែកពាណិជ្ជកម្មរបស់ក្រុមហ៊ុនទាំងឡាយ។ ទោះបីជាយ៉ាងណាក្តី វាតម្រូវឲ្យ មានតម្លាភាពកិច្ចសន្យាក្នុងការផ្សព្វផ្សាយនូវកិច្ចសន្យាផ្សេងៗ ទន្ទឹមនឹងការការពារព័ត៌មាន ពាណិជ្ជកម្មសំខាន់ៗ។ តម្លាភាព

នេះអាចដាក់បញ្ចូលព័ត៌មានស្ដីពីមូលនិធិសម្រាប់ការរុះរើដែល បង្កើតឡើងសម្រាប់ផលប្រយោជន៍ដល់អ្នកពាក់ព័ន្ធទាំងឡាយ។ គួរមានមាត្រាសម្រាប់ការ ផ្សព្វផ្សាយព័ត៌មានស្ដីពីកិច្ចសន្យាទាំងឡាយដូចជាសេចក្ដីសង្ខេបអំពីប្រការ និងល័ក្ខខ័ណ្ឌ និងការបោះពុម្ពផ្សាយនូវគំរូកិច្ចព្រមព្រៀងប្រេងកាតបច្ចុប្បន្នដែលប្រើប្រាស់ក្នុងការចរចា។ មាត្រាសម្រាប់តម្លាភាព កិច្ចសន្យាបែបនេះ គួរតម្រូវឲ្យមានការរៀបចំឡើងវិញនូវល័ក្ខខ័ណ្ឌស្ដីពីភាពសម្ងាត់នៃកិច្ចសន្យា ដើម្បីអនុញ្ញាតឲ្យមានការដាក់បង្ហាញព័ត៌មានដែលមិនមែនជាទិន្នន័យ បច្ចេកទេស កម្មសិទ្ធិ និងព័ត៌មានអាជីវកម្មសំខាន់ៗ។

## វិធានការតម្លាភាព

គួរមានបញ្ញត្តិស្ដីពីអភិបាលកិច្ចល្អនៅក្នុងការគ្រប់គ្រងនៃច្បាប់ប្រេងកាត ដើម្បីធានាថា ទំនាស់ផល ប្រយោជន៍ទាំងឡាយត្រូវបានបញ្ចៀស និងដោះស្រាយបានយ៉ាងត្រឹមត្រូវ ព្រមទាំងការហាមឃាត់ដល់មន្ត្រីរដ្ឋាភិបាលក្នុងការកាន់កាប់ផលនូវប្រយោជន៍នៅក្នុងអាជ្ញាប័ណ្ណ ឬប្រតិបត្តិការប្រេងកាត និងវិធានការផ្សេងទៀត ដូចជា វិធានក្រមសីលធម៌សម្រាប់មន្ត្រីរាជការ។ គួរមានគម្រោងការស្ដីពីវិធានការតម្លាភាពសម្រាប់អ្នកពាក់ព័ន្ធ និងភាគីទាំងអស់ដែលទាក់ទិនក្នុងវិស័យនេះ។ វិធានការ ទាំងនេះគួររួមបញ្ចូលក្រមអភិបាលកិច្ចសាជីវកម្មល្អសម្រាប់ក្រុមហ៊ុនដែលបានចុះឈ្មោះ និងក្រុមហ៊ុនរដ្ឋ ការដាក់បង្ហាញខ្លឹមសារលម្អិតនៃការបង់ប្រាក់ទៅឲ្យរដ្ឋាភិបាលម្ចាស់ផ្ទះទៅតាម កិច្ចសន្យា ដោយផ្អែកលើមូលដ្ឋាននៃកិច្ចសន្យា ការបង្ហាញប្រាក់ចំណូលតាមច្បាប់តម្រូវការបោះពុម្ពផ្សាយនូវកិច្ចសន្យា និងខ្លឹមសារនៃកិច្ចសន្យាទាំងនោះ។ គួរមាននីតិវិធីសម្រាប់ធ្វើការ ដាក់បង្ហាញនូវព័ត៌មានជាសាធារណៈទៅដល់អ្នកពាក់ព័ន្ធទាំងឡាយ និងផ្សព្វផ្សាយឲ្យបាន ទៀងទាត់នូវព័ត៌មានស្ដីពី

ប្រតិបត្តិការ និងការអភិវឌ្ឍប្រេងកាតដោយក្រុមហ៊ុន និងរដ្ឋាភិបាល ដើម្បីជាផលប្រយោជន៍ដល់អ្នកពាក់ព័ន្ធនានា និងសង្គមស៊ីវិល។

## ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

គួរមានទម្រង់បែបបទគ្រប់គ្រាន់ សម្រាប់ធ្វើការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដើម្បីទទួលបានមតិយោបល់ពីពួកគេ និងដើម្បីសម្រួលឲ្យមានការចូលរួមរបស់ពួកគេប្រកបដោយប្រសិទ្ធភាព ក្នុងដំណើរការនៃការបង្កើតច្បាប់ និងគោលនយោបាយស្តីពីប្រេងកាត រួមទាំងច្បាប់ និងគោលនយោបាយវិស័យឧស្សាហកម្មនិស្សារណកម្មដទៃទៀត។ ដំណើរការនេះ គួរដាក់បញ្ចូល នូវនីតិវិធីសម្រាប់ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធជាតិ និងអន្តរជាតិស្តីពីការអភិវឌ្ឍវិស័យ ប្រេងកាត និងវិធានការគោលនយោបាយ និងច្បាប់ ព្រមទាំងគំនិតផ្តួចផ្តើមផ្សេងៗផងដែរ។ តួនាទីរបស់សង្គមស៊ីវិលគួរត្រូវបានទទួលស្គាល់ និងជួយក្នុងការបង្កើតច្បាប់ និងគោលនយោបាយ ប្រេងកាត ក្នុងការទាក់ទងជាមួយរដ្ឋាភិបាល វិស័យឯកជន និងសាធារណជន លើកកម្ពស់ការ យល់ដឹងអំពីប្រតិបត្តិការប្រេងកាត និងលទ្ធផលរបស់វាទៅដល់ពលរដ្ឋទាំងឡាយ រួមទាំងការ គ្រប់គ្រងការរំពឹងទុករបស់សាធារណជនតាមរយៈលំហូរព័ត៌មានត្រឹមត្រូវដែលអាចជឿទុកចិត្តបាន និងក្នុងការឈ្វេងយល់អំពីអត្ថន័យ ត្រឹមត្រូវ និងលទ្ធផលនៃព័ត៌មានដែលអាចរកបាន។

# ការអនុវត្តន៍ប្រសើរជាអន្តរជាតិក្នុង ឧស្សាហកម្មប្រេងកាតអាប់ស្ទ្រីម UPSTREAM សម្រាប់អ្នកពាក់ព័ន្ធ ឈ្វេងយល់

ឯកសារនេះ បរិយាយជាសង្ខេបអំពីការអនុវត្តន៍ប្រសើរជាអន្តរជាតិសំខាន់ៗនៅក្នុងឧស្សាហកម្មប្រេងកាតផ្នែកអាប់ស្ទ្រីម (Upstream) សម្រាប់អ្នកពាក់ព័ន្ធឈ្វេងយល់។

## ការអភិវឌ្ឍវិស័យប្រេងកាត

ការអភិវឌ្ឍវិស័យប្រេងកាត រួមបញ្ចូលការអនុវត្តនូវប្រតិបត្តិការប្រេងកាត មានដូចជា ការរុករក ការអភិវឌ្ឍ និងប្រតិបត្តិការផលិតកម្ម ការស្វែងរកព្រមទាំងការអភិវឌ្ឍ និងការធ្វើពាណិជ្ជកម្ម នូវកំណប់ប្រេងកាត និងឧស្ម័ន។ ប្រតិបត្តិប្រេងកាតអាចធ្វើនៅលើដីគោក (Onshore) តំបន់ទឹករាក់ (Shallow Offshore) និងតំបន់ទឹកជ្រៅ (Deep Offshore)។ ប្រតិបត្តិការនេះត្រូវការអ្នកឯកទេសទៅ លើបច្ចេកវិទ្យា ដើមទុន ធនធានបច្ចេកទេស និងមានបទពិសោធន៍ក្នុងការអនុវត្តនូវប្រតិបត្តិការ ប្រេងកាតក្នុងនាមជាប្រតិបត្តិករប្រេងកាតអន្តរជាតិ។ សកម្មភាពរុករកប្រេងកាត គឺជាពាណិជ្ជកម្ម ដែលមានភាពប្រថុយប្រថាន ដែលមានហានិភ័យខ្ពស់ និងប្រាក់ចំណេញច្រើន ព្រមទាំងការចំណាយខាតបង់ត្រូវបានរ៉ាប់រងដោយក្រុមហ៊ុនប្រេងផ្ទាល់។

ប្រតិបត្តិការប្រេងកាត គឺជាពាណិជ្ជកម្មមួយដែលប្រតិបត្តិតាមគោលការណ៍ច្បាប់ខ្ពស់ និងត្រូវបាន គ្រប់គ្រងដោយរដ្ឋាភិបាលស្ថិតក្រោមច្បាប់ប្រេងកាត។ សកម្មភាពនេះមានផលប៉ះពាល់ដល់ បរិស្ថានយ៉ាងច្រើន ដូចជា ការធ្លាយប្រេង ការបំពុល និងការរេចរិលបរិស្ថាន។ ប្រតិបត្តិការ ប្រេងកាតត្រូវការអ្នកឯកទេស និងក្រុមហ៊ុនដែលមានសមត្ថភាពដើម្បីធ្វើជាប្រតិបត្តិករ និងបណ្តាក់ ទុនជាមួយបណ្តាក្រុមហ៊ុនផ្សេងៗ។ យន្តការចម្បងក្នុងការគ្រប់គ្រងដែលត្រូវបានប្រើប្រាស់ ជាអន្តរជាតិនៅ

ក្នុងឧស្សាហកម្មប្រេងកាត គឺយន្តការផ្តល់អាជ្ញាប័ណ្ណដើម្បីគ្រប់គ្រងប្រតិបត្តិការ ប្រេងកាត។

ប្រតិបត្តិការប្រេងកាតអាចជាប្រតិបត្តិការ អាប់ស្ទ្រីម Upstream និងដោនស្ទ្រីម Downstream។ ប្រតិបត្តិការ អាប់ស្ទ្រីមមានជាដំណាក់កាលដូចជា ដំណាក់កាលរុករក រួមមាន ការសិក្សារលកសំឡេង (Seismic) និងការខួងរុករក។ ដំណាក់កាលពិនិត្យវាយតម្លៃ រួមមាន ការវាយតម្លៃ និងពិនិត្យអង្កេតនូវរបកគំហើញ ប្រេង និងឧស្ម័នដើម្បីកំណត់ពីវិសាលភាព និងបរិមាណនៃតំបន់ប្រេង និងឧស្ម័ននានា។ ដំណាក់កាលអភិវឌ្ឍ រួមមាន ការសាងសង់ ការដំឡើង និងរៀបចំបរិក្ខារផលិតកម្ម សំណង់ និងរោងចក្រ។ ដំណាក់កាលផលិតកម្ម រួមមាន ការធ្វើអាជីវកម្ម ការនាំចេញ និងការលក់ចេញផ្សេងៗទៀត។ ប្រតិបត្តិការ ដោនទ្រីម រួមមាន ការកែច្នៃ ការចម្រាញ់ប្រេងកាត ការរក្សាទុក និងការដឹកជញ្ជូននូវផលិតផលប្រេងកាត។

## គោលនយោបាយប្រេងកាតជាតិ

ប្រទេសជាច្រើនដែលបានធ្វើកំណែទម្រង់ និងធ្វើការកែលម្អក្របខ័ណ្ឌច្បាប់លើវិស័យប្រេងកាត បានរកឃើញថា វាមានប្រយោជន៍ និងមានភាពចាំបាច់ដែលត្រូវបង្កើត និងដាក់ចេញនូវគោលនយោបាយជាតិសម្រាប់វិស័យប្រេងកាត ដូចជា ថ្មីៗនេះមានប្រទេសអ៊ុយហ្គង់ដា ក្នុងឆ្នាំ ២០០៨ ប្រទេសសារ៉ាឡេអូន ក្នុងឆ្នាំ ២០១០ ប្រទេសណាមីប៊ី ក្នុងឆ្នាំ ១៩៩៨។ ដំណើរការនេះក៏ផ្តល់ផងដែរនូវឱកាសដ៏មានតម្លៃសម្រាប់រៀបចំការពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធជាតិ និងអន្តរជាតិ និងអង្គការសង្គមស៊ីវិលទៅលើក្របខ័ណ្ឌគោលនយោបាយ ដែលបានស្នើឡើង ដើម្បីទទួលបានមតិយោបល់ផ្សេងៗទៅលើកិច្ចការនេះ ដើម្បី

ធានាថាមានការឯកភាពជាទូទៅទៅលើគោលនយោបាយប្រេងកាត និង ក្របខ័ណ្ឌច្បាប់។ ក្របខ័ណ្ឌគោលនយោបាយប្រេង និងឧស្ម័ន ជាតិ ចែងពីការទាញយក និងការប្រើប្រាស់ប្រេង និងឧស្ម័នដែលជាធនធាន មិនកកើតឡើងវិញ ត្រូវបានគ្រប់គ្រងក្នុងឥរិយាបទមួយដែលបង្កើតឲ្យ មានការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមយូរអង្វែង និងមាននិរន្តភាពសម្រាប់ ប្រទេស។ គោលបំណងសំខាន់ គឺដើម្បីផ្តល់ផលប្រយោជន៍ដល់ប្រទេស ជាតិ និងពលរដ្ឋរបស់ខ្លួនតាមរយៈការបង្កើតការងារ ការអភិវឌ្ឍជំនាញ និងសមត្ថភាពបច្ចេកទេស ដល់ប្រជាពលរដ្ឋទៅលើសេវាកម្មប្រេងកាត និងសកម្មភាពផ្សេងៗ ការបង្កើនប្រាក់ចំណូល ផលប្រយោជន៍ដល់ប្រជា ពលរដ្ឋក្នុងការប្រើប្រាស់ទំនិញ និងសេវាកម្មក្នុងស្រុក ភាពចម្រុះនៃ សេដ្ឋកិច្ច ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការកែប្រែមុខមាត់សង្គម និង សេដ្ឋកិច្ចរបស់ប្រទេសឲ្យបានលឿនទៅមុខជាលំដាប់។ ដំណើរការធ្វើ កំណែទម្រង់វិស័យប្រេងកាត រួមមានការអនុម័តច្បាប់ប្រេងកាតទំនើបថ្មី មួយ ឬ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពទៅលើច្បាប់ប្រេង កាតដែល មានស្រាប់ដែលជាការអនុវត្តនូវក្របខ័ណ្ឌគោលនយោបាយ ជាតិស្តីពីប្រេង និងឧស្ម័នប្រកបដោយ តម្លាភាព និងប្រសិទ្ធភាព។

## តួនាទីរបស់សង្គមស៊ីវិល

សង្គមស៊ីវិល មានតួនាទីសំខាន់ណាស់ក្នុងការអភិវឌ្ឍវិស័យប្រេងកាត និងក្នុងដំណើការកែ ទម្រង់វិស័យប្រេងកាត។ ការចូលរួមចំណែក សំខាន់ៗរបស់ពួកគេតាមរយៈការតស៊ូមតិ ការឃ្លេងយល់ និងការ គៀងគរ និងការជជែកពិភាក្សាជាមួយសហគមន៍នានា គឺត្រូវបានទទួល ស្គាល់នៅក្នុងដំណើការពិគ្រោះយោបល់។

## កម្មសិទ្ធិ និងការគ្រប់គ្រងវិស័យប្រេងកាត

កម្មសិទ្ធិ និងការគ្រប់គ្រងប្រេងកាតដែលមានស្រាប់នៅក្នុងប្រទេស គឺស្ថិតក្រោមយុត្តាធិការរបស់ ប្រទេសនោះដែលត្រូវទាញយក និងគ្រប់គ្រងដើម្បីទទួលបានផលប្រយោជន៍អតិបរមាដល់ពលរដ្ឋ ទាំងមូល។ គោលបំណងគឺថា ដើម្បីធានាបាននូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើវិស័យ ប្រេងកាត ហើយសកម្មភាពប្រេងកាតត្រូវបានអនុវត្តប្រកបដោយភាពឈ្លាសវៃ និងទទួលបានផល ខ្ពស់។ ក្របខ័ណ្ឌច្បាប់ដែលគាំទ្រដល់ឧស្សាហកម្មប្រេងកាត រិះរកវិធីការពារសិទ្ធិទាំងឡាយរបស់ អ្នកពាក់ព័ន្ធ និងអ្នកចូលរួមទាំងអស់នៅក្នុងឧស្សាហកម្មនេះ ព្រមទាំងពលរដ្ឋរបស់ប្រទេសនោះ ផងដែរ និងដើម្បីផ្តល់ឲ្យនូវភាពជឿជាក់ ស្ថេរភាព និងលទ្ធភាពទទួលបានផលចំណេញ និងទទួលបានប្រាក់ចំណេញសមស្របដល់វិនិយោគិន និងប្រទេសជាតិ។

## ការរៀបចំស្ថាប័ន

ទាក់ទងនឹងការរៀបចំស្ថាប័ន វាគឺជាការអនុវត្តទូទៅមួយដែលត្រូវមាននិយ័តករប្រេងកាតតែមួយគត់ ជាមួយនឹងដំណើរការធ្វើសេចក្តីសម្រេចប្រកបដោយតម្លាភាព ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ និងការទទួលខុសត្រូវខ្ពស់ក្នុងការគ្រប់គ្រង និងលើកកម្ពស់សកម្មភាពវិស័យប្រេងកាត។ អាជ្ញាធរនេះ ត្រូវបានប្រគល់ឲ្យនូវអាណត្តិទាំងស្រុងក្នុងការអនុវត្តគោលនយោបាយប្រេងកាត និងតំណាងឲ្យរដ្ឋាភិបាលនៅក្នុងការចរចាជាមួយនឹងក្រុមហ៊ុនវិនិយោគិន។ ពាក់ព័ន្ធនឹងអំណាច នៅក្នុងច្បាប់ ស្ថាប័ននិយ័តករចាំបាច់ត្រូវស្ថិតនៅក្រោមដំណើរការពិនិត្យមើល និងសម្រេចពីខុទ្ទកាល័យរដ្ឋាភិបាល ឬអន្តរក្រសួង។ លើសពីនេះទៀត គួរមានការសម្របសម្រួល និងការ ផ្លាស់ប្តូរព័ត៌មានដើម្បីធានានូវការធ្វើការងារ និង

ការសហការឲ្យបានជិតស្និទ្ធជាមួយនឹងស្ថាប័ន រដ្ឋាភិបាលដែលពាក់ព័ន្ធដទៃទៀត និង ដើម្បីធានាថា ការផ្តល់អាជ្ញាប័ណ្ណបរិស្ថាន សិទ្ធិបន្ទាប់បន្សំ ដទៃទៀត ការព្រមព្រៀងនានាដែលតម្រូវសម្រាប់ប្រតិបត្តិការប្រេងកាត ត្រូវបានធ្វើឡើងដោយ អនុលោមទាំងស្រុងទៅតាមរាល់លក្ខខណ្ឌតម្រូវដែលពាក់ព័ន្ធ។

វាជាការអនុវត្តដ៏ល្អមួយ ដើម្បីរក្សាតួនាទីរបស់ស្ថាប័ននិយ័តករឲ្យស្ថិតនៅ ជាមួយនឹងទំនួលខុស ត្រូវក្នុងការតាមដាន និងត្រួតពិនិត្យមើលទៅលើវិស័យប្រេងកាត ដែលខុសពីតួនាទីរបស់ក្រុមហ៊ុន ប្រេងកាតជាតិដែលគ្រប់គ្រងទៅលើភាគហ៊ុនរបស់រដ្ឋ នៅក្នុងប្រតិបត្តិការប្រេងកាតរបស់ក្រុមហ៊ុន ប្រេងនានា និងដើម្បីធានាថា តួនាទីទាំងនេះត្រូវបានអនុវត្តដាច់ដោយឡែកពីគ្នាតាមរយៈអង្គភាព ផ្សេងៗគ្នាដើម្បីចៀងវាងនូវទំនាស់ផលប្រយោជន៍។

## ក្តីបារម្ភរបស់ប្រទេសម្ចាស់ផ្ទះ

ក្តីបារម្ភចម្បងរបស់ប្រទេសសមី គឺទៅលើការបង្កើតទិន្នន័យភូគព្ភសាស្ត្រឲ្យបានពេញលេញ ពាក់ព័ន្ធនឹងផ្ទៃដីរបស់ប្រទេស ធានាការរុករកឲ្យបានពេញលេញនិងឆាប់រហ័សនៅតាមតំបន់ ដែលរំពឹងទុកទាំងអស់ ការអភិវឌ្ឍភ្លាមៗនិងប្រកបដោយប្រសិទ្ធភាព ទៅលើតំបន់ដែលរកឃើញប្រេង និងឧស្ម័នដែលអាចធ្វើពាណិជ្ជកម្ម ការបែងចែកប្រាក់ចំណូលឲ្យបានសមស្របរវាងប្រទេស និងក្រុមហ៊ុនប្រេងនានា ការប្រព្រឹត្តិដោយត្រឹមត្រូវទៅលើប្រជាពលរដ្ឋ និងសហគមន៍ដែលទទួល រងផលប៉ះពាល់ពីប្រតិបត្តិការប្រេងកាត ការការពារបរិស្ថាន ការអប់រំនិងបណ្តុះបណ្តាលការអភិវឌ្ឍ និងការបង្កើនជំនាញដល់ប្រជាពលរដ្ឋ ការកសាងសមត្ថភាព

ដល់ស្ថាប័ននិយ័តករ និងស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ ផល ប្រយោជន៍ដល់ប្រជាពលរដ្ឋ និងការទិញទំនិញ និងសេវាកម្មក្នុងស្រុក។

## ក្តីបារម្ភរបស់ក្រុមហ៊ុនវិនិយោគទុន

ក្តីបារម្ភចំបងរបស់ក្រុមហ៊ុនវិនិយោគ គឺទៅលើការទទួលបានសុវត្ថិភាព លើសិទ្ធិផ្តាច់មុខ ការស្តារថ្លៃ ដើមវិនិយោគឡើងវិញយ៉ាងឆាប់រហ័ស និង រកបានប្រាក់ចំណូលគ្រប់គ្រាន់ ស្ថេរភាពនៃល័ក្ខខ័ណ្ឌ សារពើពន្ធ និង លក្ខខណ្ឌច្បាប់សម្រាប់អាយុកាលនៃគម្រោងទាំងមូល អាចប្រើអាជ្ញា កណ្តាល អន្តរជាតិបាន សេរីភាពក្នុងការផ្ទេរថវិកាទៅជាប្រាក់កម្ចី គម្រោង និងការបែងចែកភាគលាភ ទៅឲ្យម្ចាស់ភាគហ៊ុនរបស់ពួកគេ។

## បញ្ញត្តិប្រតិបត្តិការប្រេងកាត

ដំណើរការប្រតិបត្តិការប្រេងកាត ត្រូវបានចែងតាមរយៈច្បាប់ បទបញ្ញត្តិ កិច្ចព្រមព្រៀង និងកិច្ចសន្យាប្រេងកាត។ ក្របខ័ណ្ឌច្បាប់គួរមានតម្លា ភាព និងព្យាយាមផ្តល់ឲ្យនូវភាពប្រាកដ ប្រជាសម្រាប់ឧស្សាហកម្មនេះ ហើយក្នុងពេលទន្ទឹមគ្នានោះ ត្រូវមានភាពបត់បែនគ្រប់គ្រាន់ ដើម្បី ស្រប តាមការផ្លាស់ប្តូរ ទៅតាមកាលៈទេសៈចាំបាច់នានាទៅលើបញ្ហាព្រួយ បារម្ភសំខាន់ៗទាំងរដ្ឋ និងវិនិយោគិន។

## ការរៀបចំច្បាប់ប្រេងកាត

ប្រភេទនៃការរៀបចំច្បាប់អាចមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងចម្រុះ។ ពាក់ព័ន្ធនឹងការរៀបចំច្បាប់ ប្រេងកាត ប្រទេសមួយចំនួនចង់រក្សាទុក គោលគំនិតរបស់ច្បាប់ប្រេងកាតឲ្យមានលក្ខណៈទូទៅ ដោយឆ្លុះបញ្ចាំង ពីគោលការណ៍សំខាន់ៗ ហើយចែងលម្អិតនៅក្នុងបទបញ្ញត្តិដែលត្រូវ បានបង្កើត ឡើងស្ថិតក្រោមច្បាប់គោល។ ដំណើរការនេះជួយសម្រួល

ដល់ការធ្វើបច្ចុប្បន្នភាព និងការពិនិត្យ កែសម្រួលទៅលើបទបញ្ញត្តិបន្តិចម្តងៗដើម្បីឆ្លើយតបទៅនឹងការកាលៈទេសៈដែលកំពុងប្រែប្រួល ដោយមិនចាំបាច់ ត្រូវឆ្លងកាត់ដំណើរការធ្វើវិសោធនកម្មច្បាប់គោលរបស់រដ្ឋសភានោះឡើយ។ ប្រទេសជាច្រើនក៏មានផងដែរនូវដំណើរការរដ្ឋសភាក្នុងការរៀបចំបទបញ្ញត្តិប្រេងកាតមុខរដ្ឋសភា សម្រាប់ដំណោះស្រាយវិជ្ជមាន ឬ អវិជ្ជមានដើម្បីឲ្យមានសុពលភាព ឬ ការអនុវត្តនូវបទបញ្ញត្តិទាំងនោះ។ វិធីសាស្ត្រនេះសន្និដ្ឋានថា រាល់បទបញ្ញត្តិចាំបាច់ទាំងអស់ពិតជាត្រូវបានប្រកាសឲ្យអនុវត្ត ដើម្បីធ្វើឲ្យគម្រោងការនេះបំពេញមុខងារបានពេញលេញ។ ប្រទេសមួយចំនួន ដូចជា រុស្ស៊ី ចិន និងអារ៉ាប់រួម ប៉ែហ្សង់ ជាដើម មិនមានច្បាប់ប្រេងកាតដែលគ្រប់ជ្រុងជ្រោយនោះទេ ក៏ប៉ុន្តែគេពឹងផ្អែកទៅលើក្របខ័ណ្ឌកិច្ចសន្យា ដូចជា កិច្ចព្រមព្រៀងប្រេងកាតបន្ថែមទៅនឹងបទបញ្ញត្តិប្រេងកាត ដើម្បីគ្រប់គ្រង ទៅលើឧស្សាហកម្មនេះ។ តួយ៉ាងប្រទេសចិន មានបទបញ្ញត្តិប្រេងកាត ស្តីពីដែនសមុទ្រ (Offshore) និង ដែនលើគោក (Onshore) នាឆ្នាំ ១៩៨២ និង ១៩៩៣។

ប្រទេសមួយចំនួនផ្សេងទៀត ដូចជា ប៉ាពូញូហ្គីនា ហ្គាណា និងសាវ៉ាឡេអូន ផ្សារភ្ជាប់សារសំខាន់យ៉ាងខ្លាំងទៅលើការបង្កើតឲ្យមាននូវប្រការនិងល័ក្ខខ័ណ្ឌអប្បបរមាសំខាន់ៗ (សូម្បីតែទៅ លើវិធានការសមស្រប ស្តីពីភាពបត់បែន) នៅក្នុងច្បាប់គោលដ៏សំខាន់ដោយមិនឲ្យមានលទ្ធភាព អាចចរចាកាត់បន្ថយពេលវេលា និងថ្លៃដើមប្រតិបត្តិការអំឡុងពេលចរចា កាត់បន្ថយវិសាលភាពសម្រាប់ការអនុវត្តសេចក្តីសម្រេចផ្នែករដ្ឋបាល ដោយការដាក់បញ្ចូលជារួមនូវគោលបំណង លក្ខណៈវិនិច្ឆ័យទៅក្នុងការគ្រប់គ្រងច្បាប់ និងដើម្បីឲ្យមានឥទ្ធិពលទៅលើការចរចាឲ្យកាន់តែ ប្រសើរឡើង និងការពារការដាក់សម្ពាធពីសំណាក់ក្រុមហ៊ុន

ប្រេងនៅក្នុងកិច្ចចរចា។ តាមរយៈនេះ ធ្វើឲ្យមាននូវអត្ថប្រយោជន៍យ៉ាងច្រើនសម្រាប់ប្រទេសទាំងឡាយ ក្នុងការស្វែងរកការអភិវឌ្ឍន៍ ធនធានធម្មជាតិរបស់ខ្លួន តាមរយៈការអនុវត្តនូវវិធីសាស្ត្រសកម្មជាមុនក្នុងការបង្កើតនូវល័ក្ខខ័ណ្ឌ អប្បបរមាសំខាន់ៗនៅក្នុងច្បាប់គោល។

## លិខិតុបករណ៍ផ្តល់អាជ្ញាប័ណ្ណ

ប្រភេទផ្សេងៗគ្នានៃអាជ្ញាប័ណ្ណប្រេងកាត និងកិច្ចព្រមព្រៀងប្រេងកាតត្រូវបានប្រើប្រាស់នៅក្នុងឧស្សហកម្មប្រេងកាត។ ប្រភេទនៃការផ្តល់អាជ្ញាប័ណ្ណដែលបានប្រើប្រាស់ អាចជាអាជ្ញាប័ណ្ណរុករក និងអាជ្ញាប័ណ្ណផលិតកម្មពីរផ្សេងគ្នា ឬ ប្រភេទអាជ្ញាប័ណ្ណរុករក និងអាជ្ញាប័ណ្ណផលិតកម្មរួមបញ្ចូលគ្នាតែមួយ ឬក៏ កិច្ចព្រមព្រៀងប្រេងកាតតែមួយគ្របដណ្តប់គ្រប់ដំណាក់កាលទាំងអស់នៃប្រតិបត្តិការប្រេងកាតអាប់ស្ទ្រីម ។ ការអនុវត្តជាទូទៅនៅក្នុងឧស្សាហកម្មនេះ គឺការប្រើប្រាស់គម្រោងការផ្តល់អាជ្ញាប័ណ្ណពីរប្រភេទផ្សេងគ្នាសម្រាប់ដំណាក់កាលរុករក និងដំណាក់កាលអភិវឌ្ឍ នៃប្រតិបត្តិការតាមរយៈការផ្តល់ឲ្យនូវអាជ្ញាប័ណ្ណរុករក និងអភិវឌ្ឍ ឬ អាជ្ញាប័ណ្ណផលិតកម្ម បើទោះបីជាមានប្រទេសខ្លះប្រើប្រាស់អាជ្ញាប័ណ្ណរួមគ្នាតែមួយហៅថា អាជ្ញាប័ណ្ណរុករកផលិតកម្មរួមសម្រាប់គ្រប់ដំណាក់កាលទាំងពីរ។ កិច្ចព្រមព្រៀងប្រេងកាត អាចមានទម្រង់ជាកិច្ចសន្យាបែងចែកផលិតកម្ម កិច្ចព្រមព្រៀងអាជ្ញាប័ណ្ណសម្បទាន ឬ កិច្ចសន្យាការងារដែលទទួលខុសត្រូវចំពោះហានិភ័យ។ វាក៏អាចមានផងដែរនូវទម្រង់ចម្រុះនៃកិច្ចព្រមព្រៀងប្រេងកាត ដែលរួមបញ្ចូលលក្ខណៈសំខាន់ៗមួយចំនួន ពីប្រភេទខុសៗគ្នានៃកិច្ចព្រមព្រៀងប្រេងកាត។

ពាក់ព័ន្ធនឹងប្រភេទនៃកិច្ចព្រមព្រៀងប្រេងកាត ភាគច្រើនពឹងផ្អែកទៅលើភាពសុាំរបស់ប្រទេសនោះជាមួយនឹងប្រភេទនីមួយៗ នៃកិច្ចព្រមព្រៀងដែលធ្លាប់បានប្រើប្រាស់ ក៏ប៉ុន្តែនៅក្នុងប្រភេទនីមួយៗនៃកិច្ចព្រមព្រៀង មានដូចជា ប្រភេទសួយសារអាករ/ពន្ធ កិច្ចព្រមព្រៀងបែងចែកផលិតផល (PSA) ឬ កិច្ចព្រមព្រៀងសេវាកម្ម រចនាសម្ព័ន្ធ និងសមាសភាគនៃកញ្ចប់សារពើពន្ធ គឺមានសារសំខាន់ ជាងប្រភេទនៃកិច្ចព្រមព្រៀងនោះ។ ការបង្កើតប្រភេទផ្សេងៗគ្នានៃកិច្ចព្រមព្រៀងចម្រុះ អាចឲ្យលក្ខខណ្ឌសារពើពន្ធដែលចង់បានសមស្របទៅនឹងវិសាលភាពដ៏ធំ ស្ថិតក្រោមកិច្ចព្រមព្រៀងប្រភេទណាមួយ។

កិច្ចព្រមព្រៀងសំខាន់ៗដែលពាក់ព័ន្ធនៅក្នុងគម្រោងមាន កិច្ចព្រមព្រៀងប្រេងកាត កិច្ចព្រមព្រៀងបណ្តាក់ទុនរួមគ្នា កិច្ចព្រមព្រៀងភាពជាប្រតិបត្តិករ កិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទាន កិច្ចព្រមព្រៀងទីផ្សារ និងកិច្ចព្រមព្រៀងបូមប្រេងឆៅ ដែលធ្វើឡើងរវាងដៃគូបណ្តាក់ទុនរួមគ្នា។ កិច្ចព្រមព្រៀងសិក្សារលកសំឡេងនិងលិខិតអនុញ្ញាត ត្រូវបានប្រើប្រាស់ដើម្បីសិក្សាពីភូគព្ភសាស្រ្ត និងរូបសាស្រ្តដី ដើម្បីទទួលបានទិន្នន័យបច្ចេកទេស ហើយលក់កញ្ចប់ទិន្នន័យនោះទៅឲ្យ ឧស្សាហកម្មនេះ ជាមួយនឹងដំណាក់កាលដេញថ្លៃជាអន្តរជាតិ។ អាជ្ញាប័ណ្ណបំពង់ប្រេង ត្រូវបានប្រើប្រាស់សម្រាប់ផ្តល់សិទ្ធិអំណាចធ្វើការសាងសង់ និងដំណើរការបំពង់ប្រេង និងឧស្ម័ន ទាំងឡាយ។

នៅក្នុងប្រទេសជាច្រើន អាជ្ញាប័ណ្ណប្រេងកាតត្រូវបានប្រើប្រាស់ស្របទៅនឹងកិច្ចព្រមព្រៀងប្រេងកាត ដែលធ្វើឡើងជាមួយនឹងក្រុមហ៊ុនប្រេងដែលរិះរកវិធីដោះស្រាយបញ្ហានានា ដែលត្រូវព្រមព្រៀងគ្នាទៅតាមមូលដ្ឋានគម្រោង ដូចជា កិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទានជាក់លាក់ និងសិទ្ធិរបស់អ្នកឲ្យខ្ចី កិច្ចព្រមព្រៀងអភិវឌ្ឍន៍ឧស្ម័នធម្មជាតិ ឬ ដើម្បីផ្តល់

នូវភាពបត់បែននៅក្នុងបញ្ហាសមស្របនានា ដែលមានសារសំខាន់ចំពោះវិនិយោគិន ដូចជា សុវត្ថិភាពមុខជំនួញ និងស្ថេរភាពនៃកិច្ចសន្យា។

ប្រទេសមួយចំនួន ដូចជា ប្រទេសឥណ្ឌូនេស៊ី ជាដើម មិនមានអាជ្ញាប័ណ្ណផ្លូវច្បាប់បែបនេះទេ ក៏ប៉ុន្តែពឹងផ្អែកទៅលើលិខិតុបករណ៍កិច្ចសន្យានៃកិច្ចព្រមព្រៀងប្រេងកាត ដែលដើរតួជាអាជ្ញាប័ណ្ណស្ថិតក្រោមគម្រោងការស្របច្បាប់របស់ខ្លួន។ វាជាការអនុវត្តទូទៅមួយដែលត្រូវមានគំរូកិច្ចព្រមព្រៀង ដែលនៅពេលខ្លះត្រូវបានចែង និងកំណត់ពីបទដ្ឋានអប្បបរមា ប្រការ និងល័ក្ខខ័ណ្ឌសម្រាប់ផ្តល់សិទ្ធិឲ្យធ្វើការរុករក និងធ្វើការអភិវឌ្ឍ ដែលបញ្ជាក់អំពីតំបន់នានាដែលអាចនឹងត្រូវធ្វើការចរចា។

## ច្បាប់ពាក់ព័ន្ធក្នុងវិស័យប្រេងកាត និងតួនាទីផ្សេងៗគ្នារបស់ច្បាប់ទាំងនោះ

ច្បាប់ប្រេងកាត គឺជាច្បាប់គោលដែលឆ្លុះបញ្ចាំងពីគោលនយោបាយប្រេងកាតជាតិ។ បទបញ្ញត្តិប្រេងកាតចែងលម្អិតអំពីជំពូក និងនីតិវិធីអនុវត្ត ដូចជា ល័ក្ខខ័ណ្ឌតម្រូវឲ្យរាយការណ៍ឲ្យបានលម្អិត អធិការកិច្ចលើប្រតិបត្តិការ ការស៊ើបអង្កេតឧប្បត្តិហេតុផ្សេងៗ រៀបចំការសិក្សាស្ទង់លេកសំលេង និងការខួងអណ្តូងប្រេង សុខភាព និងសុវត្ថិភាពនៅកន្លែងការងារ។

ច្បាប់ពន្ធលើប្រេងកាត ចែងពីការយកពន្ធលើប្រាក់ចំណូលពីប្រេងកាត ការកំណត់ប្រាក់ចំណូលជាប់ពន្ធ ការកាត់រំលោះ និងការបន្ថយ ដើមទុនត្រូវបានអនុញ្ញាតិនៅក្នុងការគណនាប្រាក់ចំណូលជាប់ពន្ធ ការអនុវត្តលើការចំណាយមូលធន ការសងបំណុលរំលោះ និងការចំណាយប្រាក់ចំណូល។

ច្បាប់បរិស្ថានចែងអំពីអាជ្ញាប័ណ្ណបរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងដំណើរការបន្ធូរបន្ថយផលប៉ះពាល់។ លើសពីនេះទៀត មានវិធានការពិសេសៗ សម្រាប់ឆ្លើយតបចំពោះឧប្បត្តិហេតុផ្សេងៗដល់បរិស្ថាន និងការស្តារឡើងវិញនូវតំបន់ដែលរកឃើញ ដូចជា មូលនិធិធ្លាយប្រេង មូលនិធិសម្រាប់ការរុះរើចេញ ឬ មូលនិធិសម្រាប់ការបោះបង់ចោល។

កិច្ចព្រមព្រៀងប្រេងកាត គឺជាលិខិតុបករណ៍កិច្ចសន្យាផ្លូវច្បាប់ដ៏សំខាន់មួយ ដែលចែងអំពីកម្មវិធីការងារនៅក្នុងអំឡុងពេលរុករក ដំណាក់កាលពិនិត្យវាយតម្លៃ អភិវឌ្ឍ និងផលិតកម្ម និងដំណើរការធ្វើសេចក្តីសម្រេចសុវត្ថិភាពមុខជំនួញរបស់វិនិយោគិន សិទ្ធិក្នុងការបន្ត សិទ្ធិធ្វើការអភិវឌ្ឍ និងសិទ្ធិទាញយកផលដែលរកឃើញ ដោយមិនឲ្យខុសកិច្ចព្រមព្រៀងការស្តារមកវិញនូវទុន វិនិយោគ និងប្រាក់ចំណូលគ្រប់គ្រាន់ត្រឡប់មកវិញសម្រាប់ការវិនិយោគ ការធានាតាមផ្លូវច្បាប់ ដូចជា ការកំណត់អ្នកឯកទេសផ្តាច់មុខ និងភាពជាអាជ្ញាកណ្តាលដើម្បីដោះស្រាយជម្លោះហេតុការណ៍ប្រធានស័ក្តិ និងដំណើរការបញ្ចប់កិច្ចសន្យា។ អាជ្ញាប័ណ្ណដទៃទៀតដែលតម្រូវឲ្យមានសម្រាប់ផលិតកម្ម អាចរួមមានអាជ្ញាប័ណ្ណនានា ដូចជា អាជ្ញាប័ណ្ណផលិតកម្មជាដើម។

## ការផ្តល់អាជ្ញាប័ណ្ណប្រេងកាត

ក្របខ័ណ្ឌគតិយុត្តិ គួរចែងពីគោលបំណងលក្ខណៈវិនិច្ឆ័យដែលត្រូវអនុវត្តសម្រាប់ការផ្តល់ អាជ្ញាប័ណ្ណ ៖. ការបែងចែងនូវសិទ្ធិដើម្បីរៀបចំប្រតិបត្តិការប្រេងកាតនៅក្នុងប្រទេស ដើម្បីធានា នូវការផ្តល់អាជ្ញាប័ណ្ណទៅឲ្យក្រុមហ៊ុនដែលមានគុណភាព និងធនធានគ្រប់គ្រាន់ និងការពារទប់ទល់ នឹងក្រុមទាំងឡាយណាដែលមិនគុណវឌ្ឍន៍គ្រប់គ្រាន់។ ការ

ផ្តល់អាជ្ញាប័ណ្ណ គឺធ្វើឡើងដោយផ្អែកទៅលើដំណើរការ និងនីតិវិធី ដេញថ្លៃ ដោយប្រកួតប្រជែងដែលត្រូវបានផ្សព្វផ្សាយប្រកបដោយតម្លាភាព ដើម្បីទទួលបាន ប្រាក់ចំណូលច្រើនបំផុតសម្រាប់ប្រទេស និង ទាក់ទាញបាននូវដៃគូដែលមានគុណភាពល្អ។ ការរៀបចំនូវដំណើរការដេញថ្លៃ គឺត្រូវបានប្រកាសនៅពេលដែលមានការពិចារណាឃើញថាមានភាពចំបាច់។ ជម្រើសទៅលើការផ្តល់អាជ្ញាប័ណ្ណនៅក្រៅដំណើរការដេញថ្លៃ ត្រូវបានអនុញ្ញាតតែ ក្នុងកាលៈទេសៈពិសេស ដូចជានៅពេលដែលដំណើរការដេញថ្លៃមិនអាចជ្រើសរើសបានក្រុមហ៊ុន ដែលស័ក្តិសម និងសូម្បីតែនៅក្រោមប៉ារ៉ាម៉ែត្រដែលបានកំណត់អនុលោមតាម គំរូ កិច្ចព្រមព្រៀងប្រេងកាត។

ដំណើរការកំណត់គុណវឌ្ឍន៍ជាមុន ដែលតាមរយៈដំណើរការនេះមានតែក្រុមហ៊ុនដែលបានកំណត់គុណវឌ្ឍន៍ជាមុន ដែលបានបំពេញតាមគោលបំណងល័ក្ខខ័ណ្ឌវិនិច្ឆ័យប៉ុណ្ណោះ ទើបត្រូវបានអនុញ្ញាតឲ្យដេញថ្លៃ ដែលជាផ្នែកមួយនៃដំណើរការដេញថ្លៃ ឬ ជាករណីពិសេស ដែលជួយដល់ដំណើរការនៃការផ្តល់អាជ្ញាប័ណ្ណ ក្នុងការធានាបាននូវឯកសារភ័ស្តុតាងបញ្ជាក់ គុណភាពអំពីអ្នកដេញថ្លៃ។ ដើម្បីឲ្យមានសមធម៌ និងមានតម្លាភាព លក្ខណៈវិនិច្ឆ័យសម្រាប់ ការបែងចែកត្រូវផ្សព្វផ្សាយដើម្បីជូនដំណឹងដល់ក្រុមហ៊ុនប្រេងកាត និងអ្នកពាក់ព័ន្ធទាំងឡាយ អំពីមូលដ្ឋាននៃការបែងចែក និងការផ្តល់អាជ្ញាប័ណ្ណដែលធ្វើឡើងជាសាធារណៈ។ ប្លុកប្រេង ដែលត្រូវបានផ្តល់ឲ្យត្រូវសម្រេចដោយច្បាប់។ ការផ្ទេរអាជ្ញាប័ណ្ណ ឬ សិទ្ធិជាប្រតិបត្តិករណាមួយ ត្រូវតែស្ថិតក្រោមការឯកភាពរបស់និយ័តករ។

## ប្រព័ន្ធកំណត់ព្រំដែនប្លុក

វាជាការអនុវត្តទូទៅមួយសម្រាប់គម្រោងការរបស់និយ័តករ ដែលត្រូវបែងពីប្រព័ន្ធកំណត់ព្រំដែនប្លុកនានា ដើម្បីសម្រួលដល់ការធ្វើអត្តសញ្ញាណកម្មឲ្យបានត្រឹមត្រូវ និងការគ្រប់គ្រងទៅលើតំបន់ដែលផ្តល់អាជ្ញាប័ណ្ណ និងគម្រោងការប្រគល់ឲ្យមកវិញ (ឧទាហរណ៍ ប្រទេសតង់ហ្សានា, ប៉ាពួនូវហ្គីនា)។ ប្លុកដែលកំណត់ព្រំដែននេះ គួរត្រូវបានចែក ឲ្យដាច់ពីគោលគំនិតនៃប្លុក កិច្ចសន្យាដែលមានលេខដាក់លាក់ពីប្លុកដែលបានកំណត់ព្រំដែនជាមូលដ្ឋានទាំងនេះ។

## រយៈពេលរុករក និងអភិវឌ្ឍន៍

ជាទូទៅ ការរុករកមានរយៈពេលប្រហែលពី ៧ ទៅ ១០ឆ្នាំ ហើយរយៈពេលផលិតកម្ម គឺចាប់ពី ២៥ ដល់ ៣០ឆ្នាំ អាស្រ័យទៅលើអាយុកាលនៃប្លុកប្រេងនីមួយៗ។ តំបន់ផ្តល់អាជ្ញាប័ណ្ណទាំងឡាយ គឺស្ថិតក្រោមល័ក្ខខ័ណ្ឌតម្រូវប្រគល់ឲ្យវិញជាកំហិតបន្តិចម្តងៗ ទៅតាមពេលវេលាកំណត់ផ្សេងៗគ្នានៅក្នុងអំឡុងពេលរុករក ដើម្បីជានាបាននូវការរុករកដោយឆាប់រហ័ស និងដោយសកម្មនៃតំបន់ អាជ្ញាប័ណ្ណ។ គម្រោងការផ្តល់អាជ្ញាប័ណ្ណទទួលស្គាល់ថា ក្រោយការរកឃើញប្រេងកាតដែលមានសក្តានុពលអាចធ្វើពាណិជ្ជកម្ម ដំណាក់កាលវាយតម្លៃ គឺតម្រូវឲ្យមានដើម្បីធ្វើការវាយតម្លៃឲ្យបាន ត្រឹមត្រូវទៅលើការរកឃើញប្រេង និងឧស្ម័ន។ ដំណាក់កាលនេះអាចមានរយៈពេលប្រហែលពី ២ ទៅ ៤ឆ្នាំ សម្រាប់ការរកឃើញប្រេង និងរហូតដល់៨ឆ្នាំ សម្រាប់ការរកឃើញឧស្ម័នធម្មជាតិ។ បន្ថែមពីនេះទៀត ក៏ត្រូវមានបញ្ញត្តិសម្រាប់រក្សាទុករហូតដល់ ៤ឆ្នាំ បន្តទៀត បន្ទាប់ពី ការរកឃើញជាក់លាក់ទ្រង់ទ្រាយតូចៗសម្រាប់រយៈពេលកំណត់ណាមួយដើម្បីផ្តល់សិទ្ធិឲ្យធ្វើពាណិជ្ជកម្ម

នូវការរកឃើញទាំងឡាយនេះ ស្របជាមួយនឹងការរកឃើញស្រដៀងគ្នាផ្សេងទៀត នៅក្នុងតំបន់ផ្តល់អាជ្ញាប័ណ្ណដោយស្ថិតក្រោមការប្តេជ្ញាចិត្តបំពេញការងារឲ្យបានសមស្របនៅក្នុង អំឡុងពេលរក្សាទុក ដែលបានអនុញ្ញាត។

## បញ្ញត្តិស្តីពីការរកឃើញ

គម្រោងការស្តីពីការរកឃើញ បានចែងអំពីនីតិវិធីផ្សេងៗដើម្បីធានាថាក្រុមហ៊ុនទាំងឡាយមិនទុក ចោលការរកឃើញនានាដែលអាចអភិវឌ្ឍបាន និងវាយតម្លៃ និងអភិវឌ្ឍ ឬក៏ ប្រគល់ឲ្យវិញនូវការរកឃើញប្រេងកាតនោះ។ ទាក់ទងនឹងការរកឃើញឧស្ម័នធម្មជាតិ ទាំងឧស្ម័នធម្មជាតិសុទ្ធ និងឧស្ម័នធម្មជាតិលាយ មានបញ្ញត្តិដាក់លាក់មួយចំនួនសម្រាប់ជួយសម្រួលដល់ការបង្កើតទីផ្សារឧស្ម័ន និងការបង្កើតគម្រោងឧស្ម័ន។

## បញ្ញត្តិស្តីពីហានិភ័យផ្តាច់មុខ

គួរមានបញ្ញត្តិស្តីពីហានិភ័យផ្តាច់មុខ នៅក្នុងកិច្ចព្រមព្រៀងប្រេងកាតដែលផ្តល់សិទ្ធិឲ្យរដ្ឋាភិបាលធ្វើការអភិវឌ្ឍ ក្រោមការចំណាយរបស់ខ្លួនផ្ទាល់ទៅលើការរកឃើញប្រេង និងឧស្ម័ន ដែលក្រុមហ៊ុន ប្រេងកាតមិនអាចយកមកធ្វើពាណិជ្ជកម្ម ឬ មិនចង់ធ្វើការអភិវឌ្ឍ។

## របបសារពើពន្ធ

របបសារពើពន្ធរិះរកវិធីផ្តល់តម្លាភាព និងការព្យាករណ៍បានដល់រដ្ឋាភិបាល វិនិយោគិន ពលរដ្ឋរបស់ប្រទេស និងអ្នកទាំងឡាយដែលធ្វើនិយ័តកម្មឧស្សាហកម្មប្រេងកាត។ ដើម្បីធានានូវភាពកើនឡើងជាលំដាប់នៃរបបសារពើពន្ធ របបសារពើពន្ធនៅក្នុងប្រទេសជាច្រើនបានដាក់បញ្ចូលបន្ថែមទៅលើសួយសារអាករ និងពន្ធលើប្រាក់ចំណូល នូវ

យន្តការបែងចែកចំណូលកើនឡើងជាលំដាប់មួយ។ ដើម្បីឲ្យមានភាពធ្វើការព្យាករណ៍បាន តម្លាភាព និងស្ថេរភាព សមាសភាគសំខាន់ៗនៃល័ក្ខខ័ណ្ឌសារពើពន្ធមានដូចជា អត្រាសួយសារអាករ អត្រាពន្ធលើប្រាក់ចំណូល និងសមាសភាគមួយចំនួននៃយន្តការបែងចែកប្រាក់ចំណូលដែលអាចកើនឡើងជាលំដាប់ គឺមិនត្រូវបានកំណត់ដោយការចរចា ទៅតាមកិច្ចសន្យានីមួយៗឡើយ ក៏ប៉ុន្តែត្រូវចែងវានៅក្នុងច្បាប់ និងបទបញ្ញត្តិនានា។

សមាសភាគផ្សេងទៀតនៃល័ក្ខខ័ណ្ឌសារពើពន្ធអាចមានដូចជា ប្រាក់រង្វាន់ចុះហត្ថលេខា និង ផលិតកម្មកំរិតមួយ សួយសារអាករ ពន្ធផ្សេងៗរួមទាំងពន្ធលើប្រាក់ចំណូលសាជីវកម្ម ការបែងចែកប្រាក់ចំណេញក្នុងករណីកិច្ចសន្យាបែងចែកផលិតផល ការចូលរួមរបស់រដ្ឋ និងយន្តការបែងចែកប្រាក់ចំណូលដែលកើនឡើងជាលំដាប់ (ដូចជា ការជួលធនធាន ឬ ពន្ធលើប្រាក់ចំណេញបន្ថែម)។ គួរមានផងដែរនូវថ្លៃឈ្នួលរដ្ឋបាល និងថ្លៃឈ្នួលទីតាំង ហើយអាចនឹងមានផងដែរនូវថ្លៃចាត់ចែងការងារសំខាន់ៗសម្រាប់ផ្ទេរអាជ្ញាប័ណ្ណរវាងក្រុមហ៊ុនប្រេង។

រចនាសម្ព័ន្ធច្បាស់លាស់ និងសមាសភាគនៃកញ្ចប់សារពើពន្ធ គឺធ្វើឲ្យមានឥទ្ធិពល និងមានជារូបរាងឡើង នៅក្នុងបរិបទនៃប្រភេទនៃការរៀបចំមួយដែលបានអនុម័តជាស្រេច ទៅតាមសេចក្តីត្រូវការរបស់វិនិយោគិន ដើម្បីឲ្យមានអត្រានៃការសងត្រឡប់វិនិយោគបានគ្រប់គ្រាន់ ហើយក្តីបារម្ភរបស់រដ្ឋាភិបាល ដើម្បីទទួលបាន ចំណែកសមហេតុផល និងប្រព័ន្ធសារពើពន្ធដែលមានកំណើន ជាលំដាប់ជាមួយនឹងពេលវេលាទទួល ប្រាក់ចំណូលសម្រាប់រដ្ឋាភិបាល និងកម្រិតប្រាក់ចំណូលរបស់រដ្ឋាភិបាលនៅក្នុងវដ្តគណនេយ្យ របស់គម្រោងនីមួយៗ។

## ការប្រមូល ការផ្ទៀងផ្ទាត់ និងការប្រើប្រាស់ប្រាក់ចំណូលពីប្រេងកាត

វាជាការអនុវត្តទូទៅមួយ ដែលត្រូវដាក់ឲ្យមាននូវប្រព័ន្ធដែលមានតម្លាភាព និងដែលអាចព្យាករណ៍ បាន សម្រាប់ការប្រមូល ការផ្ទៀងផ្ទាត់ និងការប្រើប្រាស់ប្រាក់ចំណូលពីប្រេងកាតដើម្បីជា ប្រយោជន៍ដល់មនុស្សនាពេលបច្ចុប្បន្ន និងជំនាន់ក្រោយ និងទប់ស្កាត់នូវការគេចវេសពន្ធពាណិជ្ជកម្ម និងការកំណត់តម្លៃកិច្ចការពាណិជ្ជកម្មមិនត្រឹមត្រូវ។ គួរមានវិធានការសារពើពន្ធ ដើម្បីធានាថា ប្រាក់ចំណូលត្រឹមត្រូវពីប្រេងកាត ត្រូវបានប្រមូល និងទទួលខុសត្រូវ និងវិធានការ នានាត្រូវបង្កើតឲ្យមាន ដើម្បីបង្កើតនូវយន្តការនានាជួយសម្រួល និងបង្កភាពងាយស្រួលដល់ការ គ្រប់គ្រងសារពើពន្ធ។

ដើម្បីកាត់បន្ថយនូវការរាយការណ៍មិនពិត និងការរំលោភបំពានក្នុងការកំណត់តម្លៃផ្ទេរជាអប្បរមា នោះត្រូវបង្កើតឲ្យ មាននូវវិធានការច្បាប់ និងនីតិវិធីផ្សេងៗដើម្បីធានាថា ក្រុមហ៊ុនមានឆន្ទៈពិតប្រាកដក្នុងការលក់ និងធ្វើពាណិជ្ជកម្ម ជាមួយអ្នកទិញដែលជាសម្ព័ន្ធ តែក្នុងតម្លៃមួយដោយផ្អែកទៅលើ ឬ សមមូលជាមួយនឹងការលក់ទៅឲ្យអ្នកទិញទាំងឡាយដែលមិនស្ថិតក្នុងសម្ព័ន្ធ និងអនុលោមទៅតាមប្រការ និងល័ក្ខខ័ណ្ឌដែលអាចប្រៀបធៀបបាន រវាងភាគីអ្នកទិញទាំងឡាយដែលមិនមែនជាសម្ព័ន្ធ។ នីតិវិធីនេះក៏ត្រូវយកទៅអនុវត្តផងដែរទៅលើការធ្វើលទ្ធកម្មទំនិញ និងសេវាកម្មផ្សេងៗ។ គួរមានការសម្របសម្រួល និងកិច្ចសហការគ្នា រវាងស្ថាប័នជាតិដែលពាក់ព័ន្ធដើម្បីសម្រេចបានគោលដៅ និងទិសដៅអភិវឌ្ឍ ការប្រមូលចំណូលឲ្យបានច្រើនបំផុត និងការផ្តល់ផលប្រយោជន៍បន្ថែមដល់ សហគមន៍មូលដ្ឋានឲ្យបានកម្រិតខ្ពស់បំផុតតាមដែលអាចធ្វើទៅបាន និងការការពារបរិស្ថានឲ្យ បានជាអតិបរមា។

## ការគ្រប់គ្រងប្រាក់ចំណូលពីប្រេងកាត

ការអភិវឌ្ឍវិស័យប្រេងកាត និងការប្រើប្រាស់ប្រាក់ចំណូលដែលទទួលបានពីវិស័យនេះ គួរត្រូវបានសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយនឹងផែនការអភិវឌ្ឍន៍ជាតិរបស់ប្រទេស និងការអភិវឌ្ឍ វិស័យសេដ្ឋកិច្ចផ្សេងៗទៀត។ វិធានការនានាគួរត្រូវបានដាក់ចេញដើម្បីបង្ការការប្រែប្រួល លើសលប់នៃថវិកាជាតិ ឬ ការប្រែប្រួលម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ។ ប្រាក់ចំណូលពីប្រេងកាតគួរ ត្រូវបានគ្រប់គ្រង និងប្រើប្រាស់ឲ្យបានត្រឹមត្រូវដើម្បីបង្កើតនូវភោគទ្រព្យថ្មី និងជំរុញឲ្យមានកំណើន ប្រកបដោយសមតុល្យ និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។

វិធានការសំខាន់មួយដែលត្រូវបានគេប្រើប្រាស់ នៅក្នុងប្រទេសជាច្រើនគឺការបង្កើតនូវមូលនិធិ គ្រប់គ្រងប្រាក់ចំណូលពីប្រេងកាត ដើម្បីធានានូវការគ្រប់គ្រងប្រាក់ចំណូលពីប្រេងកាតប្រកប ដោយប្រសិទ្ធភាព និងប្រើជាប្រភពថវិកាទៅថ្ងៃអនាគត ដើម្បីទ្រទ្រង់សេដ្ឋកិច្ចក្រោយពេលអស់ ប្រេង។ មិនតែប៉ុណ្ណោះ ថវិកាបែបនេះរួមចំណែកដល់ការរក្សាស្ថេរភាពតម្លៃជារួមមិនឲ្យមានភាព រង្គោះរង្គើដោយសារការឡើងចុះនៃតម្លៃប្រេង។ វិធានការនេះតម្រូវឲ្យអនុម័តច្បាប់គ្រប់គ្រង ប្រាក់ចំណូលដែលចែងពីការប្រើប្រាស់ចំណូលពីប្រេងកាត ចំនួនភាគរយដែលអាចត្រូវបាន ប្រើប្រាស់សម្រាប់ការចំណាយក្នុងពេលបច្ចុប្បន្ន និងការចំណាយសម្រាប់ការអភិវឌ្ឍន៍របស់រដ្ឋាភិបាល និងចំនួនប៉ុន្មានភាគរយត្រូវលៃទុកជាប្រាក់សន្សំ ដើម្បីប្រើប្រាស់សម្រាប់មនុស្សជំនាន់ក្រោយៗទៀត និងនីតិវិធីដើម្បីទទួលបានថវិកាទាំងនេះ។ ការធ្វើបែបនេះព្យាយាមជួយប្រទេសនានាឲ្យ ត្រៀមខ្លួចក្រោយយុគសម័យប្រេងកាតឲ្យមានវិបត្តិសេដ្ឋកិច្ចតិចតួចកំរិតអប្បរមា។ ច្បាប់គ្រប់គ្រងប្រាក់ចំណូលពីប្រេងកាតនេះ ជួយក្នុងការធានាឲ្យមានគណនេយ្យភាព និង

តម្លាភាពនៅក្នុងការ គ្រប់គ្រងធនធានប្រេង តាមរយៈការបង្កើតឲ្យមាននូវវិធានការតម្លាភាព ដើម្បីរក្សាទំនាក់ទំនងរវាង ក្រុមហ៊ុនប្រេង គ្រប់គ្រងប្រាក់ចំណូលរបស់រដ្ឋាភិបាល និងការចំណាយសាធារណៈ។

វិធានការដ៏សំខាន់នេះ បង្កើតនូវទិសដៅរួមមួយ ដូចជា គណនីប្រេងកាតជាតិជាក់លាក់ សម្រាប់ការចំណាយ និងការគ្រប់គ្រងចំណូលពីប្រេងដោយមានការកំណត់ចំនួនជាក់លាក់ ប្រចាំឆ្នាំទៅលើមូលនិធិដែលអាចផ្ទេរចូលទៅក្នុងគម្រោងថវិការដ្ឋប្រចាំឆ្នាំ និងថវិកាអចិន្ត្រៃយ៍ដែលកម្រិតទុកសម្រាប់មនុស្សជំនាន់ក្រោយ និងបង្កើតជាដើមទុនអន្តរជំនាន់ និងជានាលំហូរថវិកាសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រោយពេលអស់ធនធានប្រេង។ ការគ្រប់គ្រង និងការវិនិយោគទៅលើថវិកាអចិន្ត្រៃយ៍ ត្រូវបានចាត់តាំងទៅឲ្យគណៈកម្មាធិការវិនិយោគដែលត្រូវបានតែងតាំង ក្រោម និងអនុលោមតាមច្បាប់។ ទាំងនេះគឺជាវិធានសម្រាប់ការធ្វើសវនកម្ម តម្លាភាព និងត្រួតពិនិត្យ។ នីតិវិធីត្រួតពិនិត្យអាចមានទាំងរដ្ឋសភា ឬ គណៈកម្មការត្រួតពិនិត្យថ្នាក់ខ្ពស់ដទៃទៀតដើម្បីពិនិត្យមើល ការអនុវត្តទៅតាមច្បាប់ ជាមួយអំណាចស៊ើបអង្កេតនិងដាក់ទណ្ឌកម្ម។ ច្បាប់នេះបង្កើតផងដែរនូវ ការិយាល័យចុះឈ្មោះនិងការិយាល័យព័ត៌មានដើម្បីឲ្យសាធារណជនទទួលបាននូវច្បាប់ និងឯកសារទាំងអស់ទាក់ទងទៅនឹងសកម្មភាពប្រេង ប្រតិបត្តិការទាក់ទងទៅនឹងមូលនិធិប្រេងកាត និងបញ្ហាផ្សេងៗទៀតដែលសាធារណជនគួរយល់ដឹង។

## បទដ្ឋានរាយការណ៍ និងគណនេយ្យអន្តរជាតិ

របបសារពើពន្ធ គួរមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងគោលការណ៍នៃគំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម និងការ

អនុវត្តប្រសើរជាអន្តរជាតិដទៃទៀត។ គ្រប់ក្រុមហ៊ុន ឬអង្គភាព ដែលប្រតិបត្តិការនៅក្នុងប្រទេស គួរតម្រូវឲ្យអនុវត្តតាមរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ និងបទដ្ឋានសវនកម្ម ដែលស្របជាមួយនឹងការអនុវត្តល្អជាអន្តរជាតិ និងបទដ្ឋានគណនេយ្យ ដែលអាចទទួលយកបានជាទូទៅ បទដ្ឋានសវនកម្ម និងបទដ្ឋានរាយការណ៍។

## ដំណើរការអនុវត្តការងារ

គោលបំណងចម្បងរបស់ក្របខ័ណ្ឌច្បាប់ គឺដើម្បីធានាថា ធនធានប្រេងកាតរបស់ប្រទេសត្រូវបានរុករកយ៉ាងហ្មត់ចត់ និងប្រកបដោយប្រសិទ្ធភាពក្រោមកម្មវិធីការងារដែលបានព្រមព្រៀងគ្នា និងត្រូវបានអភិវឌ្ឍយ៉ាងមានប្រសិទ្ធផលស្របទៅតាមផែនការដែលបានអនុម័ត។ ប្រតិបត្តិករប្រេងកាតត្រូវបានតម្រូវឲ្យបង្កើតការិយាល័យ និងមានវត្តមាននៅក្នុងប្រទេស ដែលស្ថិតក្រោមច្បាប់ និងយុត្តាធិការរបស់ប្រទេសនោះ ដើម្បីធានានូវការតាមឃ្លាំមើល ប្រកបដោយប្រសិទ្ធិភាពទៅលើប្រតិបត្តិការប្រេងកាត។ ប្រតិបត្តិករត្រូវបានតម្រូវឲ្យរៀបចំប្រតិបត្តិការរបស់ខ្លួនដោយភាពវាងវៃ និងប្រសិទ្ធផលស្របទៅតាមការអនុវត្តន៍ និងបច្ចេកទេសអន្តរជាតិដែលល្អបំផុតនៅក្នុង ឧស្សាហកម្មប្រេងកាត និងមានការយកចិត្តទុកដាក់ខ្ពស់លើសុវត្ថិភាព និងបរិស្ថាន។ ប្រព័ន្ធដែលមានប្រសិទ្ធភាពសម្រាប់ការពិនិត្យតាមដាន និងការធ្វើសវនកម្មទៅលើប្រតិបត្តិការប្រេងកាត និងសម្រាប់ធ្វើអធិការកិច្ច និងលទ្ធភាពចេញចូលទៅកាន់តំបន់ប្រតិបត្តិការដើម្បីធានានូវការអនុវត្ត តាមច្បាប់ បទបញ្ញត្តិ និងល័ក្ខខ័ណ្ឌកិច្ចសន្យា ដែលត្រូវបានបង្កើត។

ក្រុមហ៊ុនទាំងឡាយត្រូវបានតម្រូវឲ្យរក្សាទុក និងទុកដាក់របាយការណ៍ពេញលេញនៃប្រតិបត្តិការប្រេងកាត រួមជាមួយនឹងទិន្នន័យទាំងអស់

ដែលប្រមូលបាន ហើយរក្សាទុកក្នុងឥរិយាបថមួយ ត្រឹមត្រូវសម្រាប់ប្រើប្រាស់ និងទុកឲ្យប្រើប្រាស់ និងយកមកប្រើប្រាស់ដោយស្ថាប័ននិយ័តករ។ ការកែប្រែផែនការ និងកម្មវិធីសំខាន់ៗ រួមទាំងកម្មវិធីការងាររុករក ផែនការវាយតម្លៃ ផែនការអភិវឌ្ឍន៍ប្លុកប្រេង ផែនការប្រចាំឆ្នាំ និងផែនការផលិតកម្មដទៃទៀត ផែនការបញ្ឈប់ និងផែនការរុះរើចេញ ត្រូវបានតម្រូវឲ្យដាក់ជូន និងមានការឯកភាពពីនិយ័តករប្រេងកាត។ ប្រតិបត្តិករត្រូវបានតម្រូវឲ្យផ្តល់របាយការណ៍ តាមពេលកំណត់ស្តីពីប្រតិបត្តិការទាំងឡាយជូន និយ័តករប្រេងកាត ហើយជូនដំណឹងភ្លាមៗទៅអាជ្ញាធរអំពីការរកឃើញណាមួយ។ វាជាការអនុវត្ត តាមបទដ្ឋានមួយដែលត្រូវមានជំពូកនានានៅក្នុងច្បាប់ ឬ បទបញ្ញត្តិដើម្បីបញ្ជាក់ពីភាពញឹកញាប់ និងបញ្ជាក់ពីមាតិកានៃរបាយការណ៍តាមពេលកំណត់ដែលក្រុមហ៊ុនត្រូវធ្វើឡើងជាទៀងទាត់ ទៅឲ្យនិយ័តករ។ ភាពជាម្ចាស់ទៅលើទិន្នន័យទាំងឡាយ គឺជាកម្មសិទ្ធិរបស់រដ្ឋ។

## របបនៃការរុះរើចេញ

របបនៃការរុះរើចេញជាមុន គឺជាលក្ខណៈសំខាន់មួយនៃក្របខណ្ឌច្បាប់ប្រេងកាតទំនើបនៅក្នុងប្រទេសជាច្រើន។ វាមានសារៈសំខាន់ ដើម្បីដោះស្រាយចំពោះការរុះរើចេញនូវឧបករណ៍ បរិក្ខារនៅប្លុកប្រេងកាត នៅចុងបញ្ចប់នៃអាយុកាលរបស់ប្លុកដែលឆ្លុះបញ្ចាំងពីនិន្នាការទំនើប និងការអនុវត្តន៍ប្រសើរជាអន្តរជាតិក្នុងប្រតិបត្តិការប្រេងកាត។ ក្រុមហ៊ុនប្រេងកាតត្រូវមានកាតព្វកិច្ចរុះរើ ចេញនូវឧបករណ៍បរិក្ខារនាចុងបញ្ចប់នៃអាយុកាលរបស់ប្លុកប្រេងដោយគោរពទៅតាមផែនការ រុះរើចេញដែលបានអនុម័ត។ ផែនការរុះរើចេញ រួមបញ្ចូល និងសម្រេច ដែលជាផ្នែកមួយនៃផែនការ អភិវឌ្ឍន៍ទៅលើការរកឃើញប្រេងកាត ហើយត្រូវបានពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាព ជាប្រចាំក្នុងអំឡុងអាយុកាលនៃប្លុក

ដូចដែលមានចែងនៅក្នុងផែនការរុះរើចេញ ដោយយោងទៅតាមប្រតិបត្តិការប្រេងកាតត្រូវបានអនុវត្តនៅក្នុងប្លុកប្រេងនោះ។

ក្រុមហ៊ុន មានកាតព្វកិច្ចត្រូវចូលរួមថវិកាទៅក្នុងមូលនិធិសម្រាប់ការរុះរើចេញដែលត្រូវបានបង្កើតឡើង សម្រាប់តែគោលបំណងផ្តល់ថវិកាដល់ប្រតិបត្តិការរុះរើចេញ ស្របទៅតាមផែនការរុះរើចេញដែលបានអនុម័តប៉ុណ្ណោះ។ ថវិកាទាំងឡាយដែលបានដាក់នៅក្នុងមូលនិធិសម្រាប់ការរុះរើចេញ នេះ គឺជាការចំណាយដែលអាចទូទាត់យកវិញបាន។ ជំពូកនានាដែលពាក់ព័ន្ធត្រូវបានចែងនៅក្នុង ច្បាប់ស្តីពីពន្ធលើប្រាក់ចំណូល ដើម្បីអាចឲ្យថវិកាដែលតម្រូវឲ្យបង់ ត្រូវបានដាក់ចូលទៅក្នុង មូលនិធិសម្រាប់ការរុះរើចេញ ហើយថវិកានេះត្រូវបានចាត់ទុកជាចំណាយប្រតិបត្តិការរបស់ ក្រុមហ៊ុនសម្រាប់គោលបំណងកំណត់នូវពន្ធប្រាក់ចំណូល និងបង្កើតនូវជំពូកសំខាន់ៗដែល ទាក់ទង ដើម្បីដោះស្រាយទៅលើការដកថវិកាចេញពីមូលនិធិសម្រាប់ការរុះរើចេញ ថវិកាបន្ថែម ដែលបានផ្តល់ដើម្បីបំពេញនូវកង្វះខាត និងចំនួនថវិកាលើស គឺរក្សាទុកនៅក្នុងមូលនិធិសម្រាប់ការរុះរើចេញ។

## ផលប្រយោជន៍ក្នុងស្រុក និងការបណ្តុះបណ្តាល

វាជាការអនុវត្តទូទៅមួយ ដែលតម្រូវឲ្យប្រតិបត្តិករប្រេងកាតចូលរួមចំណែកកសាងសមត្ថភាព កម្រិតជាតិនៅក្នុងឧស្សាហកម្មប្រេងកាត រួមមានបុគ្គលិកជាតិរបស់ក្រុមហ៊ុន ព្រមទាំងជួយពួកគេឲ្យសម្រេចបាននូវកម្រិតអ្នកឯកទេសថ្នាក់ជាតិតាមការចង់បាន និងចំណេះធ្វើជាបន្តបន្ទាប់។ សមាសភាពរបស់ផលប្រយោជន៍ក្នុងស្រុក និងការប្រើប្រាស់ទំនិញ និងសេវាកម្មក្នុងស្រុកក្នុង វិសាលភាពមួយដែលអាចធ្វើទៅបាននៅក្នុងប្រតិបត្តិប្រេងកាត គឺជាកិច្ចការដ៏សំខាន់បំផុតមួយ ចំពោះ

ប្រទេសម្ចាស់ផ្ទះ។ ជាការសំខាន់ត្រូវបង្កើតគោលដៅប្រាកដប្រជា និង ជាក់លាក់ ចាំបាច់តាមការព្រមព្រៀងគ្នានៅក្នុងអំឡុងពេលកំណត់ណាមួយ ដើម្បីសម្រេចបានតាមភាគរយ ដែលបានកំណត់នៃការផ្តល់ផលប្រយោជន៍ក្នុងស្រុកទៅលើការជួលកំលាំងពលកម្មនៅក្នុងស្រុក និង កសាងសមត្ថភាពទៅលើជំនាញផ្សេងៗ។

រដ្ឋាភិបាលរិះរកវិធីសម្របសម្រួល ឲ្យមានកិច្ចសហប្រតិបត្តិការជារចនាសម្ព័ន្ធក្នុងចំណោមឧស្សាហកម្មប្រេងកាត និងសាកលវិទ្យាល័យក្នុងស្រុកនានា សមាគមពាណិជ្ជកម្ម និងសហគមន៍នានា។ គោលបំណងទាំងនេះ ត្រូវបានសម្របសម្រួលតាមរយៈការបង្កើតមូលនិធិសម្រាប់ការអប់រំ និងបណ្តុះបណ្តាលអំពីប្រេងកាត។ មូលនិធិបែបនេះផ្តល់អាហារូបករណ៍តាមជំនាញវិស្វករបច្ចេកទេសខុសៗគ្នា ដូចជា វិស្វកម្មភូគព្ភសាស្ត្រ គណិតវិទ្យា និងបច្ចេកវិទ្យាដែលពាក់ព័ន្ធនៅក្នុងឧស្សាហកម្មប្រេងកាត ដើម្បីផ្តល់ឱកាសដល់ពលរដ្ឋឲ្យបំពេញមុខជំនាញវិជ្ជាជីវៈ និងផ្នែកសំខាន់ៗដែលប្រទេសជាតិខ្វះកម្លាំងពលកម្ម ជំនាញឯកទេស និងលើកកម្ពស់ការយល់ដឹង។

មូលនិធិនេះ ជួយលើកកម្ពស់ចំណេះដឹងទៅលើជំនាញបច្ចេកទេសទាំងនេះក្នុងវិសាលភាពទូលំទូលាយដល់ប្រជាជន តាមរយៈការបង្ហាញដល់ពួកគេចំពោះសកម្មភាពផ្សព្វផ្សាយ ដែលបានជ្រើសរើសទៅលើវិស័យដែលពាក់ព័ន្ធ និងបង្កើនការអប់រំ និងការបណ្តុះបណ្តាលលើវិស័យទាំងនេះនៅក្នុងប្រទេស តាមរយៈការលើកកម្ពស់គុណភាពបុគ្គលិកសិក្សាទៅលើមុខវិជ្ជាទាំងនេះនៅតាមគ្រឹះស្ថានឧត្តមសិក្សាផ្សេងៗគ្នា នៅក្នុងប្រទេស។ មូលនិធិនេះត្រូវបានផ្តល់តាមរយៈការផ្តល់វិភាគទានប្រចាំឆ្នាំដែលបានព្រមព្រៀងពីសំណាក់ក្រុមហ៊ុនប្រេងកាត ដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសក្រោមកិច្ចព្រមព្រៀងប្រេងកាត ឆ្ពោះទៅរកការបណ្តុះ

បណ្ដាល។ ប្រាក់វិភាគទាននេះគឺជាថ្លៃចំណាយដែលអាចទូទាត់យកវិញបាន ហើយត្រូវបានចាត់ទុកជាការចំណាយដែលកាត់ចេញពីប្រាក់ចំណូលជាប់ពន្ធសម្រាប់គោលបំណងពន្ធលើប្រាក់ចំណូល។

## វិធានការអភិបាលកិច្ចល្អ

វាជាការអនុវត្តទូទៅមួយ ដែលតម្រូវឲ្យមានវិធានការអភិបាលកិច្ចល្អសម្រាប់អនុវត្តនៅក្នុងវិស័យប្រេងកាតដើម្បីលើកកម្ពស់តម្លាភាព និងគណនេយ្យភាព បង្កើតនូវភាពជឿជាក់ ភាពប្រាកដប្រជា និងភាពសុច្ចរិតលើគ្រប់សកម្មភាពទាំងអស់ នៅក្នុងឧស្សាហកម្មប្រេងកាត រួមមានទាំងនៅក្នុងការផ្ដល់អាជ្ញាប័ណ្ណ ការធ្វើលទ្ធកម្ម ការរុករក ការអភិវឌ្ឍន៍ និងផលិតកម្ម ព្រមទាំងនៅក្នុងការគ្រប់គ្រងប្រាក់ចំណូលពីប្រេងកាតផងដែរ។ វិធានការទាំងនេះព្យាយាមលើកកម្ពស់នូវការផ្ដល់ព័ត៌មានត្រឹមត្រូវ និងទាន់ពេលវេលាតាមរយៈរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត ព្រមទាំងតាមវិធីសមស្របផ្សេងៗទៅដល់អ្នកពាក់ព័ន្ធសំខាន់ៗ និងសាធារណជន តាមរយៈការចូលរួមរបស់ពួកគេក្នុងការធ្វើសេចក្ដីសម្រេច និងដំណើរការពិគ្រោះយោបល់ និងការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការនេះ។ ជំពូកស្ដីពីអភិបាលកិច្ចល្អជាទូទៅ គឺការរឹតបណ្ដឹងទៅលើមន្ត្រីរដ្ឋចំពោះការកាន់កាប់សិទ្ធិប្រេងកាត ឬ មានផលប្រយោជន៍ផ្ទាល់ខ្លួននៅក្នុងអាជ្ញាប័ណ្ណដោយផ្ទាល់ ឬ តាមរយៈសមាជិកគ្រួសាររបស់ខ្លួន ហើយតម្រូវឲ្យមន្ត្រីរដ្ឋទាំងឡាយត្រូវផ្ដល់នូវបញ្ជីលម្អិតនៃទ្រព្យសម្បត្តិផ្ទាល់ខ្លួន។

និន្នាការអន្តរជាតិ គឺមានទំនោរទៅរកការបង្កើតឲ្យមាននូវបញ្ញត្តិស្ដីពីការផ្សព្វផ្សាយព័ត៌មានស្ដីពី កិច្ចសន្យាប្រេងកាតដែលរួមមាន សេចក្ដីសង្ខេបអំពីប្រការ និងល័ក្ខខ័ណ្ឌនានា និងគំរូកិច្ចព្រមព្រៀងប្រេងកាតដែលត្រូវ

បានប្រើប្រាស់ក្នុងការចរចា។ មាននិន្នាការឆ្ពោះទៅរកការបោះផ្សាយកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាដើម្បីតម្លាភាព និងគណនេយ្យភាពជាសាធារណៈ ការបោះផ្សាយប្រាក់ចំណូលពីប្រេងកាតដែលទទួលបានពីក្រុមហ៊ុនប្រេងទាំងឡាយ ការបង្កើតវិធានការតម្លាភាពប្រាក់ចំណូលនៅក្នុងសហរដ្ឋអាមេរិក ទ្វីបអឺរ៉ុប និងនៅក្នុងប្រទេសមួយចំនួនទៀត គំនិតផ្តួចផ្តើម EITI តម្លាភាពក្នុងការប្រមូលប្រាក់ចំណូលពីប្រេងកាត និងតម្លាភាពក្នុងការគ្រប់គ្រងប្រាក់ចំណូល និងគណនេយ្យភាពប្រាក់ចំណូល។ ប្រទេសមួយចំនួន ដូចជា ទីម័រខាងកើត និងហ្គាណា ផ្សព្វផ្សាយនូវកិច្ចព្រមព្រៀងប្រេងកាតរបស់ខ្លួន ហើយច្បាប់តម្លាភាពរបស់ប្រទេសកុងហ្គោនាពេលបច្ចុប្បន្ន ចែងអំពីការផ្សព្វផ្សាយកិច្ចសន្យាប្រេង កិច្ចសន្យារុករករ៉ែ និងកិច្ចសន្យាព្រៃឈើដែលត្រូវចេញផ្សាយនៅក្នុងអំឡុងពេលពីរខែបន្ទាប់ពីបានធ្វើឡើង។ នៅក្នុង ប្រទេសមួយចំនួនដូចជា ហ្គាណា និងសារ៉ាឡេអូន បានចុះហត្ថលេខាលើកិច្ចសន្យា ដែលត្រូវបាន ផ្តល់សច្ចាប័នដោយរដ្ឋសភាជាតិមុននឹងកិច្ចសន្យាទាំងនោះចូលជាធរមាន។ នៅក្នុងប្រទេសមួយ ចំនួនដូចជា លីបេរីយ៉ា ប៉េរូ អេក្វាឌ័រ សៅតូមីព្រីនស៊ីព មានការដាក់បង្ហាញនូវកិច្ចសន្យា ហើយកិច្ចសន្យាទាំងនោះ អាចទាញយកពីក្នុងគេហទំព័របាន។ រដ្ឋធម្មនុញ្ញឆ្នាំ២០១០ របស់ប្រទេសនីហ្សេ តម្រូវឲ្យធ្វើការដាក់បង្ហាញនូវកិច្ចសន្យាឧស្សាហកម្មនិស្សារណកម្ម។

## គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI)

គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI) នៅក្នុងឧស្សាហកម្មប្រេងកាតលើកកម្ពស់ការផ្សព្វផ្សាយ និងការដាក់ជូននូវព័ត៌មានស្តីពីប្រាក់ចំណូលពីប្រេងកាតដោយផ្អែក ទៅលើគោលការណ៍លក្ខណៈវិនិច្ឆ័យ និងនីតិវិធីទាំងឡាយដែលត្រូវបានបង្កើតឡើងដោយ

EITI ។ គោលការណ៍ទាំងនេះតម្រូវឲ្យធ្វើការផ្សព្វផ្សាយជាទៀងទាត់ និងធ្វើសវនកម្មដោយឯករាជ្យ គ្រប់ប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់រវាងក្រុមហ៊ុន និងរដ្ឋាភិបាល។ ដើម្បីទទួលបានជាសមាជិក EITI ប្រទេសនោះត្រូវតែបំពេញទៅតាមសូចនាករជាក់លាក់របស់ EITI ហើយបន្ទាប់មកការអនុវត្ត EITI តម្រូវឲ្យមានវិធានការដើម្បីពង្រឹងតម្លាភាពប្រាក់ចំណូលពីធនធាន។ ដើម្បីទទួលបានជា សមាជិកពេញសិទ្ធិរបស់ EITI ប្រទេសនោះត្រូវឆ្លងកាត់ដោយជោគជ័យនូវការវាយតម្លៃដោយ ឯករាជ្យទៅលើភាពរីកចម្រើនដែលសម្រេចបាន និងសុពលភាពEITI ក្នុងរយៈពេលពីរឆ្នាំ។ បច្ចុប្បន្ននេះEITI មានសមាជិកពេញសិទ្ធិចំនួន១១ប្រទេស គិតនៅត្រឹមឆ្នាំ ២០១១។

គំនិតផ្តួចផ្តើម EITI ត្រូវទទួលបាននូវការគាំទ្រពីច្បាប់តម្លាភាព ក្នុងគោលបំណងពង្រឹងតម្លាភាព ហិរញ្ញវត្ថុរបស់សាជីវកម្ម ដូចជាតម្រូវការរបាយការណ៍ហិរញ្ញវត្ថុរបស់អាមេរិក នៅក្នុងច្បាប់ Dodd Frank ដែលតម្រូវឲ្យក្រុមហ៊ុននិស្សារណកម្មទាំងអស់ ដែលបានចុះឈ្មោះក្នុងទីផ្សារភាគហ៊ុន សហរដ្ឋអាមេរិក រាយការណ៍អំពីការបង់ប្រាក់ជូនរដ្ឋាភិបាលនៅក្នុងប្រទេសដែលក្រុមហ៊ុន ទាំងនោះធ្វើប្រតិបត្តិការ។ ស្រដៀងគ្នានេះដែរច្បាប់ស្តីពីតម្លាភាពត្រូវបានរៀបចំធ្វើនៅក្នុងទ្វីប អឺរ៉ុប។ សហភាពអឺរ៉ុបបានប្រកាសពីផែនការរបស់ខ្លួន ក្នុងការណែនាំពីការរាយការណ៍កម្រិត ប្រទេសសម្រាប់វិស័យព្រៃឈើ និងនិស្សារណកម្ម។ វិធានការច្បាប់ផ្សេងទៀត រួមបញ្ចូលនូវច្បាប់ ប្រឆាំងអំពើពុករលួយនៅក្នុងសហរដ្ឋអាមេរិក និងក្នុងចក្រភពអង់គ្លេស ព្រមជាមួយនឹងការដាក់ទោសទណ្ឌ។ ក្រុមហ៊ុនប្រេងកាតទាំងឡាយដែលបានចុះបញ្ជីក៏ត្រូវស្ថិតក្រោមល័ក្ខខ័ណ្ឌតម្រូវឲ្យ ដាក់បង្ហាញក្នុងទីផ្សារហ៊ុនផងដែរ។

EITI ព្យាយាមពង្រឹងអភិបាលកិច្ចដោយបង្កើនតម្លាភាព និងគណនេយ្យភាពតាមរយៈការធ្វើ សវនកម្មឯករាជ្យ និងការសម្រុះសម្រួលជាសាធារណៈនូវការបង់ប្រាក់ដែលធ្វើឡើងដោយ ក្រុមហ៊ុន និងប្រាក់ចំណូលដែលទទួលបានដោយរដ្ឋាភិបាល។ EITI រំពឹងទៅលើតួនាទី និងវិធីសាស្ត្ររបស់អ្នកពាក់ព័ន្ធចម្រុះ រួមមាន រដ្ឋាភិបាល ក្រុមហ៊ុនវិនិយោគិន និងសង្គមស៊ីវិល នៅក្នុងដំណើរការនេះ។

## សុខភាព សុវត្ថិភាព និងបរិស្ថាន

ការប្រែបាច់បញ្ចូលគ្នានូវកិច្ចការសុខភាព និងសុវត្ថិភាពតែមួយ និងដំណើរការផ្តល់អាជ្ញាប័ណ្ណ បរិស្ថានសម្រាប់កិច្ចការពារបរិស្ថានស្របទៅតាមបទដ្ឋាន បង្កើតនូវបទដ្ឋានបរិស្ថានអន្តរជាតិ នៅក្នុងការកសាងផែនការ និងការអភិវឌ្ឍវិស័យប្រេងកាត គឺជាលក្ខណៈដ៏សំខាន់មួយនៃការអនុវត្តបែបទំនើប។ កិច្ចការនេះរួមបញ្ចូលបុរេវាយតម្លៃ និងការឯកភាព ទៅលើការសិក្សាអំពីហេតុប៉ះពាល់បរិស្ថាននៅតាមដំណាក់កាលសំខាន់ៗនៃប្រតិបត្តិការប្រេងកាត និងសំណើសុំធ្វើការកាត់បន្ថយផលប៉ះពាល់បរិស្ថានជាអវិជ្ជមាននៃប្រតិបត្តិការទៅលើបរិស្ថាន ធ្វើឡើងដោយស្ថាប័ននិយ័តករជាតិ សមស្របណាមួយមុនពេលចាប់ផ្តើមប្រតិបត្តិការ។ គោលការណ៍តឹងរឹង ចាប់បង្ខំ និងការទទួលខុសត្រូវចំពោះការបំពុលដែលបណ្តាលមកពីប្រតិបត្តិការប្រេងកាត គឺជាការអនុវត្ត មួយដែលត្រូវបានបង្កើតឡើង។ បន្ថែមពីលើកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ និងថ្នាក់សាកលលោក ក្នុងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ កិច្ចការពារបរិស្ថាន និងការពិចារណាទៅលើការពិត ដែលថាឧស្ម័នធម្មជាតិ គឺជាធនធានដ៏មានតម្លៃមួយ ការអនុវត្តជាអន្តរជាតិ គឺសម្រាប់ឲ្យ រដ្ឋាភិបាលរក្សានូវគោលនយោបាយនៃការមិនដុត

ឧស្ម័នចោល ឬបញ្ចេញចោលនូវឧស្ម័នធម្មជាតិ លើកលែងតែសម្រាប់ការពិសោធន៍ សង្គ្រោះបន្ទាន់ និងដើម្បីហេតុផលសុវត្ថិភាពតែប៉ុណ្ណោះ។

## ការបៀរប្រេង និងការបំពុលបរិស្ថាន

ពាក់ព័ន្ធនឹងការធ្លាយប្រេង និងការបំពុលបរិស្ថាននៅក្នុងប្រទេសមួយចំនួន មានការពិចារណាទៅលើការបង្កើតមូលនិធិគ្រប់គ្រងបរិស្ថាន ក្នុងគោលបំណងប្រើប្រាស់មូលនិធិនេះ ជាជម្រើសចុងក្រោយសម្រាប់ការធ្លាយប្រេង និងការបំពុលបរិស្ថានធំៗផ្សេងទៀតដែលបណ្តាលមកពីប្រតិបត្តិការប្រេងកាតរបស់ក្រុមហ៊ុនប្រេង ដែលកំពុងតែប្រតិបត្តិការនៅក្នុងប្រទេស។ មូលនិធិនេះ គឺជាយន្តការចុងក្រោយបង្អស់ ដោយសារមិនមានវិធីណាផ្សេងមកជំនួសចំពោះការទទួលខុសត្រូវទាំងស្រុង របស់អ្នកបំពុលចំពោះការខូចខាតបរិស្ថានឡើយ ក៏ប៉ុន្តែវានឹងដើរតួនាទីសំខាន់សម្រាប់រដ្ឋាភិបាលនៅពេលដែលក្រុមហ៊ុនដែលពាក់ព័ន្ធ (ដែលភាគច្រើនអាចជាក្រុមហ៊ុនប្រេងខ្នាតតូច ឬ មធ្យម) មិនមានសមត្ថភាពបំពេញការទទួលខុសត្រូវរបស់ខ្លួនដោយសារតែក្ស័យធន។ ការផ្តល់ហិរញ្ញប្បទានសម្រាប់មូលនិធិគ្រប់គ្រងបរិស្ថានបែបនេះ តាមរយៈការបង់ពន្ធអាករប្រចាំឆ្នាំដែលតម្រូវទៅលើក្រុមហ៊ុន ដែលកំពុងប្រតិបត្តិការផលិតប្រេងទាំងអស់នៅក្នុងប្រទេស ដែលអាចនឹងបង្កើតជាថ្លៃចំណាយប្រតិបត្តិការដែលអាចទូទាត់យកវិញបានរបស់ក្រុមហ៊ុនដែលពាក់ព័ន្ធ ។ មិនតែ ប៉ុណ្ណោះគួរមានផងដែរនូវការដាក់បំពេញវិញតាមភាពចាំបាច់ដើម្បីរក្សាមូលនិធិនោះឲ្យមានកម្រិតដូចដើម បន្ទាប់ពីហេតុការណ៍បំពុលបរិស្ថានដែលបានតម្រូវឲ្យប្រើប្រាស់មូលនិធិនោះជាចាំបាច់។ បទពិសោធន៍កន្លងមកជាអន្តរជាតិ ការផ្តល់ប្រាក់វិភាគទានទៅក្នុងមូលនិធិធ្លាយប្រេងកើតឡើង នៅក្នុងអំឡុងដំណាក់កាលរុករក តាមរយៈការយកពន្ធលើក្រុមហ៊ុនទាំងឡាយ ដែលកំពុងខួងរុករកសម្រាប់អណ្តូង

នីមួយៗដែលបានខូង ៩. នៅក្នុងប្រទេសណូវ៉ែលហ្សឺឡង់។ នៅក្នុងប្រទេសអូស្ត្រាលី អាជ្ញាធរជាតិសុវត្ថិភាពជាតិក្នុងដែនសមុទ្រ ដែលបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៣ បានទទួលជំនួយថវិកាតាមរយៈថ្លៃឈ្នួល និងពន្ធសុវត្ថិភាពពីឧស្សាហកម្ម ដែលមានដូចជា ពន្ធស៊ើបអង្កេតសុវត្ថិភាព ការវាយតម្លៃសុវត្ថិភាពរបស់រោងចក្រ និងពន្ធផែនការគ្រប់គ្រងសុវត្ថិភាពបំពង់ប្រេងប្រចាំឆ្នាំ។ នៅក្នុងប្រទេសផ្សេងទៀត មូលនិធិគ្រប់គ្រងបរិស្ថាន ទទួលបានថវិកាតាមរយៈពន្ធផលិតកម្មរបស់ក្រុមហ៊ុនផលិតប្រេង។

## តម្រូវសម្រាប់ទីផ្សារក្នុងស្រុក

វាជាការអនុវត្តទូទៅមួយ ដែលតម្រូវឲ្យក្រុមហ៊ុនប្រេងកាតផ្គត់ផ្គង់ប្រេង និងឧស្ម័នដែលខ្លួនបានផលិតក្នុងសមាមាត្រសមស្របមួយ ដើម្បីបំពេញតម្រូវការទីផ្សារក្នុងស្រុក របស់ប្រទេសទៅតាមតម្លៃនៅលើទីផ្សារ។

## បញ្ញត្តិរក្សាសិទ្ធិកែប្រែ (Grandfathering Provisions)

វាជាការអនុវត្តទូទៅមួយ ដែលត្រូវមានបញ្ញត្តិស្តីពីការរក្សាសិទ្ធិកែប្រែសមស្របសម្រាប់អាជ្ញាប័ណ្ណ និងកិច្ចព្រមព្រៀងប្រេងកាតចាស់ដែលនៅមានសុពលភាព នៅពេលដែលច្បាប់ប្រេងកាតថ្មីមួយត្រូវបានអនុម័ត។ ជំពូកទាំងនេះ ទាក់ទងនឹងការចែងអំពីការកែប្រែសមស្របសម្រាប់រក្សាទុកសិទ្ធិប្រេងកាតដែលមានស្រាប់ និងផ្តល់នូវយន្តការសមស្របនានាសម្រាប់ធ្វើការកែប្រែកិច្ចព្រមព្រៀងប្រេងកាត ដែលមានស្រាប់ចូលទៅក្នុងគម្រោងការនៃច្បាប់ថ្មី ដោយផ្អែកលើមូលដ្ឋានឯកភាពរួមដែលគូភាគីព្រមទទួលយក។

## ការគ្រប់គ្រងការរំពឹងទុករបស់សាធារណជន

បទពិសោធន៍អន្តរជាតិរបស់ប្រទេសផលិតជាច្រើនបានបង្ហាញថា ការរកឃើញ និងការផលិតធនធានប្រេងកាតបង្កើតនូវការរំពឹងទុកយ៉ាងខ្លាំងនៅក្នុងចំណោមសាធារណជន ដោយសារតែ សារៈសំខាន់ដែលឃើញយ៉ាងច្បាស់ និងផលប្រយោជន៍ភ្លាមៗនៃសកម្មភាពប្រេងកាតនៅក្នុង ប្រទេស។ ដើម្បីគ្រប់គ្រងការរំពឹងទុករបស់សាធារណជន រដ្ឋាភិបាលផ្តល់ឲ្យសាធារណជននូវ ព័ត៌មានត្រឹមត្រូវ និងទាន់ពេលវេលាទាក់ទងនឹងសកម្មភាពទាំងឡាយក្នុងវិស័យនេះ ដើម្បី ដោះស្រាយ និងទប់ស្កាត់ការរំពឹងទុកដែលមិនត្រឹមត្រូវ និងទប់ទល់ការផ្សព្វផ្សាយព័ត៌មានដែល មិនពិត និង/ឬ ដែលមិនមានមូលដ្ឋានច្បាស់លាស់អំពីប្រតិបត្តិការប្រេងកាត។

ការអប់រំដល់អ្នកពាក់ព័ន្ធទាំងឡាយ នៅគ្រប់កម្រិតទាំងអស់អំពីផលជាក់ស្តែងនៃប្រតិបត្តិការប្រេងកាត និងលំហូរប្រាក់ចំណូលទៅកាន់រដ្ឋាភិបាល ព្រមទាំងលក្ខណៈ និងការកំណត់ពេលវេលានៃការទទួលផលប្រយោជន៍ពិតប្រាកដទៅដល់សាធារណជន ពីប្រតិបត្តិការប្រេងកាត ចាំបាច់ ត្រូវផ្តល់ឲ្យក្នុងលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាព។ វាមានសារៈសំខាន់ណាស់ដែលថា នៅក្នុងដំណើរការនេះ រដ្ឋាភិបាលចូលរួមជាមួយនឹងអ្នកពាក់ព័ន្ធទាំងអស់ និងអង្គការសង្គមស៊ីវិល ដើម្បីដោះស្រាយបញ្ហាកង្វល់របស់អ្នកពាក់ព័ន្ធទាំងឡាយ។

**សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន**
វីឡាលេខ ៨៨ ផ្លូវលេខ ៤៦៨ សង្កាត់ទួលទំពូង ១
ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ៨៥៥ ២៣ ២១៧ ៦០៧
អ៊ីម៉េល ៖ com@crrt-cambodia.org
វិបសាយ ៖ www.crrt-cambodia.org